ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ត្រួតពិនិត្យ ប្រចាំឆ្នាំ ២០២៥

អគ្គនាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



ក្នុងឆ្នាំ២០២៥ ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅស្ថិតក្រោមភាពមិនប្រាកដប្រជាខ្លាំង ដែលកើតចេញពីភាពតានតឹងភូមិសាស្ត្រនយោបាយ សង្គ្រាមពាណិជ្ជកម្ម បម្រែបម្រួលនៃគោលនយោបាយរូបិយវត្ថុ បច្ចេកវិទ្យា និងបញ្ហាប្រឈមមួយចំនួន រួមមាន ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជម្លោះនៅមជ្ឈិមបូព៌ា កម្រិតអត្រាការប្រាក់ខ្ពស់នៅលើទីផ្សារអន្តរជាតិ ការកំណត់ពន្ធគយបដិការរបស់សហរដ្ឋអាមេរិក និងការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចជាដើម។ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា នៅឆ្នាំ២០២៥ សេដ្ឋកិច្ចពិភពលោកបន្តមានកំណើនក្នុងអត្រា ៣,២% ដោយក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មានកំណើន ១,៦% សេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មានកំណើន ៤,២% និងសេដ្ឋកិច្ចប្រទេសអាស៊ាន-៥[១] មានការថយចុះមកត្រឹម ៤,៣%។ ចំណែកសេដ្ឋកិច្ចកម្ពុជាមានកំណើន ៥% នៅឆ្នាំ២០២៥ ប៉ុន្តែសម្រាប់ឆ្នាំ២០២៦ ទាំងមូល កំណើននេះត្រូវបានរំពឹងថាអាចនឹងមានការថយចុះបន្តិច ដោយសារផលប៉ះពាល់មកលើការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក ក្នុងការដាក់ចេញគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាមេរិក និងការអូសបន្លាយនៃជម្លោះព្រំដែនកម្ពុជា-ថៃ។ ក្នុងន័យនេះ ការរក្សាបានសន្តិភាព និងស្ថិរភាពនយោបាយ គឺជាធាតុដ៏សំខាន់ និងមិនអាចកាត់ផ្តាច់ចេញពីកំណើននេះ ហើយក៏ជាសមិទ្ធផលដ៏ធំធេងរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានខិតខំអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រយៈពេលជាងពីរឆ្នាំកន្លងមក។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បន្តចូលរួមយ៉ាងសកម្មក្នុងការគាំទ្រគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដូចជា "យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨" របស់រាជរដ្ឋាភិបាលដែលមានគោលដៅគាំពារ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់អ្នកប្រកបអាជីវកម្ម និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏ដូចជាអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីក្លាយទៅជាកម្លាំងចលករដ៏សំខាន់រួមចំណែកជាអតិបរមាក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន តាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ ក្នុងការអនុវត្តផែនការសកម្មភាពនានា ស្របតាមយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងបានកំពុងធ្វើបច្ចុប្បន្នកម្មលើយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០២៦-២០៣០។ ធនាគារជាតិនៃកម្ពុជា បន្តយកចិត្តទុកដាក់ខ្ពស់ដោយសហការជាមួយភាគីពាក់ព័ន្ធ រៀបចំប្រព័ន្ធវដ្តករសាស្ត្រស្តីពី ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា និងផែនទីមគ្គុទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីចូលរួមគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព។

---

[១] រួមមាន៖ ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ

ធនាគារជាតិនៃកម្ពុជា បន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាចូលរួមគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលស្របតាមគោលនយោបាយរាជរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ក្នុងការជំរុញសេដ្ឋកិច្ច និងសង្គមឌីជីថល។ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ត្រូវបានពង្រីកវិសាលភាពជាបន្តបន្ទាប់ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់និងដៃគូសហការនានាដើម្បីសម្រួលដល់ការវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍ ឱ្យមានភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។

ក្នុងស្ថានភាពសេដ្ឋកិច្ចសកលនិងតំបន់មានភាពមិនប្រាកដប្រជាកាន់តែខ្ពស់ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចាំបាច់ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នខ្ពស់ ក្នុងគោលដៅពង្រឹងភាពធន់ទាំងក្នុងកម្រិតគ្រឹះស្ថាននីមួយៗ និងប្រព័ន្ធទាំងមូល។ ក្នុងន័យនេះ ការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានអនុវត្តប្រកបដោយភាពហ្មត់ចត់ ដើម្បីវាយតម្លៃហានិភ័យ និងដាក់ចេញនូវវិធានការបុរេសកម្មនានា។ ធនាគារជាតិនៃកម្ពុជា ក៏បានដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួន និងកំពុងរៀបចំបទប្បញ្ញត្តិមួយចំនួនទៀត ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃប្រព័ន្ធធនាគារកម្ពុជាឱ្យស្របតាមស្តង់ដាត្រួតពិនិត្យអន្តរជាតិ ជាពិសេសស្តង់ដាបាសែល។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ការអនុគ្រោះដល់អតិថិជនជាជនភៀសសឹក ពលករត្រលប់មកពីប្រទេសថៃ និងយោធិនដែលធ្វើប្រតិបត្តិការដោយផ្ទាល់ក្នុងសមរភូមិប្រយុទ្ធ ដើម្បីសម្រាលបន្ទុកតាមលទ្ធភាពដែលអាចធ្វើទៅបាន ជាពិសេសការលុបចោលបំណុលចំពោះគ្រួសារជាយោធិនពលី ឬពិការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ធនាគារជាតិនៃកម្ពុជា បន្តការយកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស ទាំងសមត្ថភាពជំនាញ និងឯកទេសកម្ម តាមរយៈការបណ្តុះបណ្តាលនានាដែលត្រូវបានរៀបចំឡើងជាប្រចាំ ទាំងក្នុងនិងក្រៅប្រទេស និងការសិក្សាតាមរយៈប្រព័ន្ធអនឡាញ ក៏ដូចជាការចែករំលែកចំណេះដឹងផ្ទៃក្នុងផងដែរ។ ជាក់ស្តែង មន្ត្រីត្រួតពិនិត្យត្រូវបានអនុញ្ញាតឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលជាច្រើនដើម្បីទទួលបានទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង សំដៅពង្រឹងគុណវុឌ្ឍិរបស់មន្ត្រីត្រួតពិនិត្យ និងជំរុញការអនុវត្តការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាព។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះផ្តល់នូវប្រភពព័ត៌មានយ៉ាងសំខាន់សម្រាប់បង្កើនការយល់ដឹងបន្ថែមអំពីប្រព័ន្ធធនាគារនៅកម្ពុជា។

ថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦

**ជា សិរី**

**ទេសាភិបាល**

**ធនាគារជាតិ នៃ កម្ពុជា**

# ខ្លឹមសារសង្ខេប

សេដ្ឋកិច្ចពិភពលោកនៅតែប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារជម្លោះប្រដាប់អាវុធ ភាពតានតឹងភូមិសាស្ត្រនយោបាយ ការអូសបន្លាយសង្គ្រាមរុស្ស៊ី–អ៊ុយក្រែន ជម្លោះនៅមជ្ឈិមបូព៌ា អត្រាការប្រាក់ខ្ពស់នៅទីផ្សារអន្តរជាតិ និងការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច។ បរិបទទាំងនេះ បានបន្តបង្កសម្ពាធដល់កំណើនសេដ្ឋកិច្ចសកល និងតំបន់។ សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២៥ ត្រូវរំពឹងថានឹងសម្រេចបាន កំណើនក្នុងរង្វង់ ៥% ដែលអត្រានេះទាបជាងការរំពឹងទុក ដោយសារកម្ពុជានៅបន្តរងផលប៉ះពាល់ពីបរិបទសកល ព្រមទាំងការអូសបន្លាយនៃការជម្លោះព្រំដែនកម្ពុជា-ថៃ។

ប្រព័ន្ធធនាគារនៅកម្ពុជា បន្តរក្សាបាននូវភាពធន់ដែលឆ្លុះបញ្ចាំងតាមរយៈការរក្សាបានអនុបាតសាធនភាព និងអនុបាតក្របខ័ណ្ឌសន្ទនីយភាព លើសកម្រិតអប្បបរមាដែលកំណត់ដោយបទប្បញ្ញត្តិប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា។ លទ្ធភាពស្វែងរកប្រាក់ចំណេញបានបង្ហាញពីភាពប្រសើរតាមរយៈកំណើននៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក។ ទន្ទឹមនេះ ប្រព័ន្ធធនាគារនៅកម្ពុជា បន្តរួមចំណែកយ៉ាងសំខាន់ដល់ការគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ ជាក់ស្តែង ទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារនៅកម្ពុជា មានកំណើន ៨,២% ក្នុងនោះឥណទានអតិថិជនមានកំណើន ៥,៤% ខណៈប្រាក់បញ្ញើអតិថិជនមានកំណើន ១២,៤% និងមូលនិធិភាគទុនិកមានកំណើន ១២,២% ធៀបនឹងឆ្នាំ២០២៤ ដែលបង្ហាញពីជំនឿទុកចិត្តរបស់សាធារណជននិងវិនិយោគិនមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ អនុបាតឥណទានមិនដំណើរការបន្តកើនឡើងដល់ ៨,៦%។ យ៉ាងណាមិញ អនុបាតឥណទានមិនដំណើរការសុទ្ធមានត្រឹមតែ ២,៤% ខណៈអនុបាតសំវិធានធនធៀបនឹងឥណទានមិនដំណើរការមាន ៧១,២% ដែលបង្ហាញពីលទ្ធភាពរបស់ប្រព័ន្ធធនាគារក្នុងការទប់ទល់នឹងហានិភ័យឥណទាន។ បន្ថែមលើនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាទូទៅបានអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តតាមដាន និងត្រួតពិនិត្យជាប្រចាំចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង។ ការត្រួតពិនិត្យ បានពង្រីកវិសាលភាពទៅលើប្រព័ន្ធធនាគារស្នូល សុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា ឧបទ្ទវហេតុព័ត៌មានវិទ្យា ជាដើម ដោយសារការប្រឈមនឹងហានិភ័យដែលអាចកើតមានឡើងពីបច្ចេកវិទ្យា។

ដើម្បីពង្រឹងគុណភាពទិន្នន័យ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តរៀបចំនិងអភិវឌ្ឍទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីៗបន្ថែមទៀតស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ ជាមួយគ្នានេះ ផ្ទាំងបង្ហាញព័ត៌មានហិរញ្ញវត្ថុ ក៏បាននិងកំពុងរៀបចំនិងអនុវត្តជាបណ្តើរៗសម្រាប់ពង្រឹងការតាមដានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការវិភាគស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញប្រកាសស្តីពី វិធានការប៉ុរេសកម្មចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងកែសម្រួលប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ធនាគារជាតិនៃកម្ពុជា បានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាបន្តបន្ទាប់ ដោយរួមបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងមុខងារសំខាន់ៗ ដែលជួយសម្រួល និងលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់របស់អតិថិជនឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងប្រកបដោយទំនុកចិត្ត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថល។

ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា ដោយបានដាក់ចេញនូវឧបករណ៍សំខាន់ៗ ដូចជា មូលបត្រអាចជួញដូរបាន ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា និងឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី ដែលអាចជួយបំពេញតម្រូវការសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាពដោយផ្អែកលើមូលដ្ឋានគោលនយោបាយ និងគំនិតផ្តួចផ្តើមជាតិពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) និងយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹតភាពកាបូនរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអភិវឌ្ឍផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីជាមគ្គុទេសក៍ក្នុងការជំរុញវិស័យនេះ និងប្រព័ន្ធវគ្គីករសាស្ត្រ ដើម្បីចាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ច ឬគម្រោងវិនិយោគ។

ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តផែនការសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ សំដៅពង្រីកលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងអត្ថប្រយោជន៍ពេញលេញសម្រាប់ប្រជាជន និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងតាមដាននិងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងត្រៀមលក្ខណៈរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០២៦-២០៣០។

ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៅក្នុងវិស័យហិរញ្ញវត្ថុ និងបំពេញតម្រូវការក្នុងការបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យ ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងវគ្គចែករំលែកចំណេះដឹងផ្ទៃក្នុងត្រូវបានរៀបចំដើម្បីពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ។ មន្ត្រីត្រួតពិនិត្យក៏បានចូលរួមដោយផ្ទាល់ក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធ ក្នុងប្រទេសនិងក្រៅប្រទេស ដែលរៀបចំ

ដោយស្ថាប័នអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលស៊ាសិន ជាដើម។

ធនាគារជាតិនៃកម្ពុជា បន្តជំរុញ និងបង្កើតកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ទ្វេភាគី និងពហុភាគី រវាងប្រតិបត្តិករសេវាធនាគារ អាជ្ញាធរត្រួតពិនិត្យ អាជ្ញាធរពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដែលបានជំរុញសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានផ្តល់កិច្ចសហការសរុបចំនួន ២៧០ ករណី ជាមួយ ក្រសួងយុត្តិធម៌ សាលាដំបូងរាជធានី-ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នផ្សេងៗ។ ធនាគារជាតិនៃកម្ពុជាក៏បាននិងបន្តផ្តល់កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិរួមមាន៖ មូលនិធិរូបិយវត្ថុអន្តរជាតិ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ភ្នាក់ងារវាយតម្លៃ S&P Global Ratings និងក្រុមហ៊ុន Tris Rating ក្នុងការផ្លាស់ប្តូរបទពិសោធ ចំណេះដឹង និងស្តង់ដាត្រួតពិនិត្យជាដើម។

# មាតិកា


**អារម្ភកថា** ..... i

**ខ្លឹមសារសង្ខេប** ..... iii

**អក្សរកាត់** ..... ix

**បញ្ជីក្រាហ្វ និងតារាង** ..... xi

**១. ការអភិវឌ្ឍប្រព័ន្ធធនាគារ** ..... **១**

១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ..... ១

១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ..... ១

១.២.១. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ..... ៣

១.២.១.១. ប្រតិបត្តិការនៃធនាគារពាណិជ្ជ ..... ៣

១.២.១.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ..... ៦

១.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ..... ៨

១.២.២.១. ប្រតិបត្តិការនៃធនាគារឯកទេស ..... ៨

១.២.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ..... ១០

១.២.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ..... ១២

១.២.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ ..... ១៣

១.២.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ..... ១៤

១.២.៤. ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម រុក្ខប្រម៉ាញ់ និងនេសាទ ..... ១៤

១.២.៥. ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុន មីក្រូ តូច និងមធ្យម ..... ១៦

១.២.៦. ឥណទាន និងប្រាក់បញ្ញើអតិថិជន នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមបណ្តារាជធានី-ខេត្ត ..... ១៦

១.២.៧. ប្រាក់បញ្ញើតាមប្រភេទអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ..... ១៨

១.២.៨. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ..... ១៩

១.២.៩. អាជីវកម្មប្តូរប្រាក់ ..... ១៩

១.៣. ប្រតិបត្តិការនៃទីផ្សារអន្តរធនាគារ ..... ២០

**២. ការវិវឌ្ឍនៃក្របខ័ណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិ.......................................២០**
២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ.......................................២០
២.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.......................................២១
២.២.១. សកម្មភាពនៃការត្រួតពិនិត្យ.......................................២១
២.២.១.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ...........២១
២.២.១.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ.......២២
២.២.១.៣. ការត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ...២៣
២.២.២. ឥណទានរៀបចំឡើងវិញ.......................................២៤
២.៣. ហិរញ្ញវត្ថុប្រកបដោយចីរភាព.......................................២៤
**៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់.............២៧**
៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ.......................................២៧
៣.១.១. បច្ចេកវិទ្យាហិរញ្ញវត្ថុ.......................................២៧
៣.១.២. ប្រព័ន្ធទូទាត់សងប្រាក់.......................................២៨
៣.១.៣. ការអនុវត្តស្តង់ដាគណនេយ្យ.......................................២៩
៣.១.៤. ការចែករំលែកព័ត៌មានឥណទាន.......................................៣០
៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា.......................................៣២
៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ.......................................៣៣
៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុ.......................................៣៣
៣.២.១.២. ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ....៣៤
៣.២.១.៣. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី...៣៤
៣.២.១.៤. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "គោះ! និយាយពីលុយៈ តក់ៗពេញបំពង់".......................................៣៥
៣.២.១.៥. គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍".......................................៣៥
៣.២.២. កិច្ចការពារអតិថិជន.......................................៣៥
៣.២.៣. កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ ស្តីពី "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា".......................................៣៦
**៤. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការ....................៣៧**

៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ............................................................. ៣៧
៤.២. កិច្ចសហប្រតិបត្តិការជាតិ ......................................................................... ៣៨
៤.២.១. អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ........................................................ ៣៨
៤.២.២. កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ........................................................ ៣៨
៤.២.៣. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ........................ ៣៨
៤.៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ ................................................................... ៣៩
៤.៣.១. គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ ................................................................................ ៣៩
៤.៣.២. សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ ........................................................... ៣៩
៤.៣.៣. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ............................................................. ៤០
៤.៣.៤.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិផ្សេងៗ ...................................... ៤១
**បញ្ជីឧបសម្ព័ន្ធ** .................................................................................... **៤២**

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញភាសាអង់គ្លេស | ពាក្យពេញភាសាខ្មែរ |
|---|---|---|
| ADA | Appui au Développement Autonome | អង្គការ Appui au Développement Autonome |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFI | Alliance for Financial Inclusion | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ |
| AI | Artificial Intelligence | បញ្ញាសិប្បនិម្មិត |
| AMRO | The ASEAN+3 Macroeconomic Research Office | ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី |
| APRACA | Asia-Pacific Rural and Agricultural Credit Association | សមាគមឥណទានកសិកម្ម និងជនបទ សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក |
| ATM | Automatic Teller Machine | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ |
| BFIs | Banks and Financial Institutions | គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ |
| BSRS | Bank Supervision Reporting System | ប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ |
| CFIU | The Cambodia Financial Intelligence Unit | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| CIFRS | Cambodian International Financial Reporting Standard | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា |
| CIFRS for SMEs | Cambodian International Financial Reporting Standard for SMEs | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម |
| ECL | Expected Credit Loss | ការខាតបង់ឥណទានរំពឹងទុក |
| e-KYC | Electronic Know Your Customer | ការចុះឈ្មោះអតិថិជនជាអេឡិចត្រូនិក |
| e-Wallet | Electronic Wallet | កាបូបអេឡិចត្រូនិក |
| FAST | Fast Payment System | ប្រព័ន្ធសេវាទូទាត់រហ័ស |
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| IT Incidents | Information Technology Incidents | ឧបទ្ទវហេតុព័ត៌មានវិទ្យា |

| | | |
|---|---|---|
| K-Score | Khmer Score | ខ្មែរ ស្កុរ |
| LPCO | Liquidity Providing Collateralized Operation | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| MDI | Microfinance Deposit-taking Institution | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ |
| MFI | Microfinance Institution | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MSMEs | Micro, small, and medium enterprises | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| MLF | Marginal Lending Facility | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NCD | Negotiable Certificate of Deposit | មូលបត្រអាចជួញដូរបាន |
| NDC | Nationally Determined Contribution | ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| NPL | Non-Performing Loan | ឥណទានមិនដំណើរការ |
| POS | Point of Sale Machine | ម៉ាស៊ីនទូទាត់បណ្ណឥណពន្ធ-ឥណទាន |
| RCI | Rural Credit Institution | គ្រឹះស្ថានឥណទានជនបទ |
| ROA | Return on Asset | ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម |
| ROE | Return on Equity | ប្រាក់ចំណេញធៀបនឹងដើមទុន |
| SEACEN | The South East Asian Central Banks Research and Training Centre | មជ្ឈមណ្ឌល ស៊ាសិន |
| SDG | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNESCAP | United Nations Economic and Social Commission for Asia and the Pacific | គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ |
| WB | World Bank | ធនាគារពិភពលោក |

# បញ្ជីក្រាហ្វ និងតារាង

## ក្រាហ្វ

ក្រាហ្វ ១ ៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................ ២
ក្រាហ្វ ២ ៖ ឥណទាននិងប្រាក់បញ្ញើអតិថិជន នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ២
ក្រាហ្វ ៣ ៖ ធនាគារពាណិជ្ជ - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច ........ ៤
ក្រាហ្វ ៤ ៖ ធនាគារពាណិជ្ជ - ឥណទាន និងប្រាក់បញ្ញើអតិថិជន .................................. ៤
ក្រាហ្វ ៥ ៖ ធនាគារពាណិជ្ជ - ចំនួនគណនីឥណទាន និងគណនីប្រាក់បញ្ញើអតិថិជន ...... ៤
ក្រាហ្វ ៦ ៖ ធនាគារពាណិជ្ជ - ចំនួនបណ្ណឥណទាន និងបណ្ណឥណពន្ធ ............................ ៥
ក្រាហ្វ ៧ ៖ ធនាគារពាណិជ្ជ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ ........... ៥
ក្រាហ្វ ៨ ៖ ធនាគារពាណិជ្ជ - អនុបាតឥណទានមិនដំណើរការ ........................................ ៦
ក្រាហ្វ ៩ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន ............... ៦
ក្រាហ្វ ១០ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទាននិងប្រាក់បញ្ញើអតិថិជន. ៧
ក្រាហ្វ ១១ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទានតាមវិស័យ ស្ថាប័ន និង សកម្មភាព សេដ្ឋកិច្ច ........................................................................ ៧
ក្រាហ្វ ១២ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - អត្រាការប្រាក់មធ្យមលើឥណទាន និង ប្រាក់បញ្ញើ .......................................................................... ៨
ក្រាហ្វ ១៣ ៖ ធនាគារឯកទេស - ទ្រព្យសកម្ម និងកំណើន .............................................. ៩
ក្រាហ្វ ១៤ ៖ ធនាគារឯកទេស - ឥណទានអតិថិជន និងកំណើន ...................................... ៩
ក្រាហ្វ ១៥ ៖ ធនាគារឯកទេស - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច ............. ៩
ក្រាហ្វ ១៦ ៖ ធនាគារឯកទេស - អត្រាការប្រាក់មធ្យមលើឥណទាន ................................. ១០
ក្រាហ្វ ១៧ ៖ ធនាគារឯកទេស - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ ...... ១០
ក្រាហ្វ ១៨ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន ....... ១១
ក្រាហ្វ ១៩ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - កំណើនឥណទានអតិថិជន... ១១
ក្រាហ្វ ២០ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច ........................................................................ ១១
ក្រាហ្វ ២១ ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - អនុបាតប្រាក់ចំណេញនិងឥណទាន មិនដំណើរការ ........................................................................ ១២
ក្រាហ្វ ២២ ៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ - ភតិសន្យាហិរញ្ញវត្ថុតាមវិស័យ ស្ថាប័ន និង សកម្មភាពសេដ្ឋកិច្ច ........................................................................ ១៣

ក្រាហ្វ ២៣ ៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ - អនុបាតប្រាក់ចំណេញនិងភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ ........ ១៣

ក្រាហ្វ ២៤ ៖ ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងប្រព័ន្ធធនាគារនៅកម្ពុជា ........ ១៥

ក្រាហ្វ ២៥ ៖ ចំណែកទីផ្សារឥណទានទៅដំណាំកសិផល ........ ១៥

ក្រាហ្វ ២៦ ៖ ចំណែកទីផ្សារឥណទានទៅវិស័យស្រូវ-អង្ករ ........ ១៦

ក្រាហ្វ ២៧ ៖ ចំណែកឥណទានអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមបណ្តារាជធានី-ខេត្ត ........ ១៧

ក្រាហ្វ ២៨ ៖ ចំណែកទីផ្សារប្រាក់បញ្ញើអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមបណ្តារាជធានី-ខេត្ត ........ ១៨

ក្រាហ្វ ២៩ ៖ ចំណែកទីផ្សារប្រាក់បញ្ញើអតិថិជនតាមប្រភេទអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ........ ១៨

ក្រាហ្វ ៣០ ៖ អាជីវកម្មប្តូរប្រាក់ - ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត ........ ១៩

ក្រាហ្វ ៣១ ៖ អាជីវកម្មប្តូរប្រាក់ - ចំនួនលិខិតអនុញ្ញាតនៅតាមបណ្តាខេត្ត ........ ២០

ក្រាហ្វ ៣២ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - គ្រឹះស្ថានជាសមាជិក ........ ៣០

ក្រាហ្វ ៣៣ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំណៀតឥណទាន និងចំនួនគណនី ........ ៣១

ក្រាហ្វ ៣៤ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំណៀតឥណទានបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក ........ ៣១

ក្រាហ្វ ៣៥ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - ការប្រើប្រាស់របាយការណ៍ឥណទាន ........ ៣២

## តារាង

តារាង ១ ៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមប្រភេទភាគទុនិក ........ ១

តារាង ២ ៖ សូចនាករសំខាន់ៗរបស់ធនាគារពាណិជ្ជ ........ ៣

តារាង ៣ ៖ សូចនាករសំខាន់ៗរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ........ ១២

## ប្រអប់

ប្រអប់ទី ១ ៖ យន្តការឆ្លើយតបទៅនឹងបញ្ជីទណ្ឌកម្មរបស់ការិយាល័យគ្រប់គ្រងទ្រព្យសកម្មបរទេស នៃ ក្រសួងរតនាគារសហរដ្ឋអាមេរិក ........ ២៦

ប្រអប់ទី ២ ៖ សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទិវាសន្សំអាស៊ាន" ........ ៣៣

# ទិន្នន័យទាំងអស់មិនទាន់ត្រូវបានធ្វើសវនកម្ម
# និងត្រូវបានរាយការណ៍ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍប្រព័ន្ធធនាគារ

### ១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ស្ថិតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការលើកកម្ពស់គុណភាពនៃការត្រួតពិនិត្យ ព្រមទាំងការដាក់ចេញនូវបទប្បញ្ញត្តិ វិធានការចាំបាច់និងទាន់ពេលជាបន្តបន្ទាប់ ដើម្បីរក្សាបាននូវភាពធន់និងជំនឿទុកចិត្តរបស់សាធារណជនជាតិនិងអន្តរជាតិមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន៖ ធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៥ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១២ គ្រឹះស្ថានឥណទានជនបទ ៨៩ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣០ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៥ និងអាជីវកម្មប្តូរប្រាក់ ៣.៣៩៣។

តារាង១៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមប្រភេទភាគទុនិក (គិតជាភាគរយ)

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-២៤ | ធ្នូ-២៥ | ធ្នូ-២៤ | ធ្នូ-២៥ | ធ្នូ-២៤ | ធ្នូ-២៥ | ធ្នូ-២៤ | ធ្នូ-២៥ |
| **គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ៣០,៣ | ៣៥,០ | ២៧,១ | ៣១,៩ | ៣៤,៧ | ៤០,១ | ២៧,៨ | ២៨,០ |
| ភាគទុនិកបរទេស | ៦៦,៥ | ៦១,៣ | ៦៨,៥ | ៦២,៧ | ៦៥,៣ | ៥៩,៩ | ៦៤,០ | ៦៤,២ |
| **គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ០,៩ | ០,៧ | ១,២ | ០,៩ | - | - | ៣,១ | ២,៧ |
| ភាគទុនិកបរទេស | ២,៣ | ៣,០ | ៣,២ | ៤,៥ | - | - | ៥,១ | ៥,០ |
| **សរុបគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ៣១,២ | ៣៥,៧ | ២៨,៣ | ៣២,៨ | ៣៤,៧ | ៤០,១ | ៣០,៩ | ៣០,៧ |
| ភាគទុនិកបរទេស | ៦៨,៨ | ៦៤,៣ | ៧១,៧ | ៦៧,២ | ៦៥,៣ | ៥៩,៩ | ៦៩,១ | ៦៩,៣ |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

### ១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ៨,២% ដល់ ៤០២,៣ ទ្រីលានរៀល (១០០,២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនមានកំណើន ៥,៤% ដល់ ២៥៥,៥ ទ្រីលានរៀល (៦៣,៧ ប៊ីលានដុល្លារអាមេរិក)។ ជាមួយគ្នានេះ ប្រាក់បញ្ញើអតិថិជនមានកំណើន ១២,៤% ដល់ ២៥៧,៦ ទ្រីលានរៀល (៦៤,២ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិភាគទុនិក មានកំណើន ៧,៥% ដល់ ៧៦,១ ទ្រីលានរៀល (១៩ ប៊ីលានដុល្លារអាមេរិក)។

ក្រាហ្វ ១៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




ក្រាហ្វ ២៖ ឥណទាន និងប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនឥណទាន និងប្រាក់បញ្ញើ ដោយក្នុងនោះ ចំនួនគណនីប្រាក់បញ្ញើអតិថិជន និងគណនីឥណទានអតិថិជនកើនឡើងដល់ ៣១,៨ លានគណនី និង ៤,៥ លានគណនី រៀងគ្នា។ បណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៧២២ ទីតាំង មានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិចំនួន ៦.០០៤ គ្រឿង និងម៉ាស៊ីនទូទាត់បណ្ណឥណពន្ធ-ឥណទានចំនួន ៤៣.០៨១ គ្រឿង ដែលធ្វើឱ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួល និងទូលំទូលាយជាងមុន។

ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព សម្រួលការទូទាត់ពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។ នវានុវត្តន៍នៃឧបករណ៍ទូទាត់សងប្រាក់ និងការពង្រីកបណ្តាញទូទាត់ដែលមានសក្តានុពលបានធ្វើឱ្យការប្រើប្រាស់សេវាទូទាត់សងប្រាក់របស់សាធារណជន និងសហគ្រាសកាន់តែប្រសើរជាងមុន។

ជារួម ប្រព័ន្ធធនាគារនៅកម្ពុជា បន្តរួមចំណែកយ៉ាងសំខាន់ដល់ការគាំទ្រសកម្មភាពសេដ្ឋកិច្ច តាមរយៈការផ្តល់សេវាធនាគារដ៏សម្បូរបែប និងងាយស្រួល។

## ១.២.១. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រួមមាន៖ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៣៨៩,៩ ទ្រីលានរៀល (៩៧,២ ប៊ីលានដុល្លារអាមេរិក) ដែលរួមចំណែក ៩៦,៩% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ទន្ទឹមនេះ ប្រាក់បញ្ញើអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បន្តមានកំណើនខ្ពស់ ១២,៤% ដល់ ២៥៧,៦ ទ្រីលានរៀល (៦៤,២ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនកើនឡើង ៥,៣% ដល់ ២៤៤ ទ្រីលានរៀល (៦០,៨ ប៊ីលានដុល្លារអាមេរិក)។

### ១.២.១.១. ប្រតិបត្តិការនៃធនាគារពាណិជ្ជ

ទ្រព្យសកម្មសរុបរបស់ធនាគារពាណិជ្ជបន្តកើនឡើង ៨,៧% ដល់ ៣៧១,៩ ទ្រីលានរៀល (៩២,៧ ប៊ីលានដុល្លារអាមេរិក)។ ប្រភពមូលនិធិរបស់ធនាគារពាណិជ្ជ មានដូចជា ប្រាក់បញ្ញើអតិថិជន ២៤៦ ទ្រីលានរៀល (៦១,៣ ប៊ីលានដុល្លារអាមេរិក) មូលនិធិភាគទុនិក ៦៨,១ ទ្រីលានរៀល (១៧ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិកម្ចី ១៣,៩ ទ្រីលានរៀល (៣,៥ ប៊ីលានដុល្លារអាមេរិក)។

តារាង ២៖ សូចនាករសំខាន់ៗរបស់ធនាគារពាណិជ្ជ (គិតជាភាគរយ)

| សូចនាករ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២០,៤ | ១១,៧ | ១៦,៤ | ៨,១ | ៨,៧ |
| កំណើនឥណទានអតិថិជន | ២៦,៤ | ១៨,៣ | ១៤,៩ | ៣,១ | ៥,៣ |
| កំណើនប្រាក់បញ្ញើអតិថិជន | ១៧,៨ | ៨,៥ | ២១,៣ | ១៦,៩ | ១២,២ |
| ទ្រព្យសកម្មធៀប ផ.ស.ស | ១៦០,៤ | ១៦៤,៦ | ១៨០,៦ | ១៨៤ | ១៨៦ |
| ឥណទានអតិថិជនធៀប ផ.ស.ស | ១០៣ | ១១២ | ១២១,៣ | ១១៦,៩ | ១១៤,៤ |
| ប្រាក់បញ្ញើអតិថិជនធៀប ផ.ស.ស | ៩៤,៨ | ៩៤,៥ | ១០៨,១ | ១១៧,៩ | ១២៣ |

ឥណទានអតិថិជនបានកើនឡើង ៥,៣% ដល់ ២២៨,៧ ទ្រីលានរៀល (៥៧ ប៊ីលានដុល្លារអាមេរិក)។ ឥណទានជាប្រភពទុនយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងបានបែងចែកទៅតាមប្រភេទជំនួញសំខាន់ៗ រួមមាន៖ សកម្មភាពផ្នែកអចលនទ្រព្យ ២៣,៤% អាជីវកម្មលក់រាយ ១៦,៤% សំណង់ ១០,៨% សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្តត់ផ្គង់សេវាកម្ម ៩,៨% អាជីវកម្មលក់ដុំ ៨,៩% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៨,៥% កម្មន្តសាលកម្ម ៤,៦% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៤,២% ការដឹកជញ្ជូននិងការស្តុកទុក ២,៧% និងឥណទានផ្សេងៗ ១០,៧%។

ក្រាហ្វ ៣៖ ធនាគារពាណិជ្ជ - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច




ប្រាក់បញ្ញើអតិថិជននៅធនាគារពាណិជ្ជបានកើនឡើង ១២,២%។ ចំណែកទីផ្សារប្រាក់បញ្ញើរួមមាន៖ ឯកត្តជន ៧១,៩% សហគ្រាសអាជីវកម្ម ១៧,១% និងផ្សេងៗ ១១%។ ចំនួនគណនីប្រាក់បញ្ញើ និងឥណទានបានបន្តកើនដល់ ២៨,៣ លានគណនី និង ២,៧ លានគណនី រៀងគ្នា។ ការណ៍នេះក៏ឆ្លុះបញ្ចាំងនូវជំនឿទុកចិត្តរបស់សាធារណជនដែលបន្តមានមកលើធនាគារពាណិជ្ជនៅកម្ពុជាផងដែរ។

ក្រាហ្វ ៤៖ ធនាគារពាណិជ្ជ - ឥណទាន និងប្រាក់បញ្ញើអតិថិជន




ក្រាហ្វ ៥៖ ធនាគារពាណិជ្ជ - ចំនួនគណនីឥណទាន និងគណនីប្រាក់បញ្ញើអតិថិជន




ការប្រើប្រាស់បណ្ណឥណទាន ជំនួសសាច់ប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយបណ្ណឥណទានបានកើនដល់ ១៧៨.១៧២ បណ្ណ ខណៈចំនួនបណ្ណឥណពន្ធបានធ្លាក់ចុះត្រឹម ៨.៨៧០.៨៩០ បណ្ណ ដោយសារនវានុវត្តន៍បច្ចេកវិទ្យាប្រព័ន្ធទូទាត់សងប្រាក់។

ធនាគារពាណិជ្ជបាននិងកំពុងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនជាលំដាប់ ដោយម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិកើនឡើងដល់ ៥.៧៨៦ គ្រឿង ព្រមទាំងបានពង្រីកបន្ថែមនូវសេវាហិរញ្ញវត្ថុឌីជីថលផងដែរ។ ទន្ទឹមនេះ ធនាគារពាណិជ្ជក៏បន្តផ្តល់សេវាយ៉ាងទូលំទូលាយតាមរយៈ ១.៧៥៦ សាខាទូទាំងប្រទេស។

ក្រាហ្វ ៦៖ ធនាគារពាណិជ្ជ - ចំនួនបណ្ណឥណទាន និងបណ្ណឥណពន្ធ




អត្រាការប្រាក់ជាមធ្យមលើប្រាក់បញ្ញើមាន ៥,៣% ចំពោះប្រាក់រៀល និង ៤,៨% ចំពោះប្រាក់ដុល្លារអាមេរិក ប៉ុន្តែអត្រាការប្រាក់ជាមធ្យមលើឥណទានអ្នកប្រើប្រាស់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក មាន ១២,៩% និង ១០,៩% រៀងគ្នា។

ក្រាហ្វ ៧៖ ធនាគារពាណិជ្ជ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ




អនុបាតដើមទុនសរុប និងអនុបាតគ្របខណ្ឌសន្ទនីយភាពមាន ២២% និង ១៩១,៣% រៀងគ្នា។ លទ្ធភាពស្វែងរកប្រាក់ចំណេញត្រូវបានឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មមាន ១,១% និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកមាន ៦%។

ទន្ទឹមនេះ អនុបាតឥណទានមិនដំណើរការបានកើនឡើងពី ៧,២% ក្នុងឆ្នាំ២០២៤ ដល់ ៨,៣% ក្នុងឆ្នាំ២០២៥ (អនុបាតឥណទានមិនដំណើរការសុទ្ធមានត្រឹម ២,៤%)។ ធនាគារពាណិជ្ជបានធ្វើចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិ ក៏ដូចជាបានចាត់ថ្នាក់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងគណនាការខាតបង់រំពឹងទុកស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ក្រាហ្វ ៨៖ ធនាគារពាណិជ្ជ - អនុបាតឥណទានមិនដំណើរការ




## ១.២.១.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើង ២% ដល់ ១៨ ទ្រីលានរៀល (៤,៥ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនក៏បានកើនឡើង ៦,៥% ដល់ ១៥,៣ ទ្រីលានរៀល (៣,៨ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានចំនួន ១១,៧ ទ្រីលានរៀល (២,៩ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិភាគទុនិក ៣,៦ ទ្រីលានរៀល (០,៩ ប៊ីលានដុល្លារអាមេរិក)។

ក្រាហ្វ ៩៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានបន្តចូលរួមចំណែកផ្តល់ឥណទានដល់ការពង្រីកមុខរបរអាជីវកម្ម និងកសិកម្ម។ ជាក់ស្តែង ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានផ្តល់ទៅកាន់សកម្មភាពសេដ្ឋកិច្ច រួមមាន៖ កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ២៣,៨% អាជីវកម្មលក់រាយ ២២,១% សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ២០,៦% សកម្មភាពផ្នែកអចលនទ្រព្យ ៧,៨% សំណង់ ៤% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៣,៩% អាជីវកម្មលក់ដុំ ៣,១% ការដឹកជញ្ជូននិងការស្តុកទុក ៣,១% កម្មន្តសាលកម្ម ១,៤% និងឥណទានផ្សេងៗ ១០,២%។

ក្រាហ្វ ១០៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ -ឥណទាននិងប្រាក់បញ្ញើអតិថិជន




ក្រាហ្វ ១១៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានចូលរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ តាមរយៈបណ្តាញប្រតិបត្តិការចំនួន ៨៣៥ ទីតាំង សម្រាប់ផ្តល់សេវាហិរញ្ញវត្ថុនៅទូទាំងប្រទេស ហើយចំនួនគណនីប្រាក់បញ្ញើបានបន្តកើនដល់ ៣,៥ លានគណនី និងគណនីឥណទាន ៩៥៣.៦២៣ គណនី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបាននិងកំពុងផ្តល់សេវាហិរញ្ញវត្ថុសម្បូរបែប ដូចជា សេវាឥណទាន ប្រាក់បញ្ញើ ផ្ទេរប្រាក់ ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ ជាដើម។

អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានថយចុះ បើធៀបនឹងឆ្នាំ២០២៤ ដោយអត្រាការប្រាក់ជាមធ្យមលើប្រាក់បញ្ញើជារៀលមាន ៥,៦% និងជាប្រាក់ដុល្លារអាមេរិកមាន ៥,៧%។ ចំណែកអត្រាការប្រាក់ជាមធ្យមលើឥណទានអ្នកប្រើប្រាស់ជារៀល

បានថយចុះពី ១៧,៥% ក្នុងឆ្នាំ២០២៤ មកត្រឹម ១៦,៣% ក្នុងឆ្នាំ២០២៥ ខណៈដែលអត្រាការប្រាក់ជាមធ្យមលើឥណទានអ្នកប្រើប្រាស់ជាដុល្លារអាមេរិក បានថយចុះបន្តិចបន្តួចពី ១៦,៥% ក្នុងឆ្នាំ២០២៤ មកត្រឹម ១៦,២% ក្នុងឆ្នាំ២០២៥។

ក្រាហ្វ ១២៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រក្សាបាននូវអនុបាតប្រុងប្រយ័ត្នលើសកម្រិតបទប្បញ្ញត្តិដែលត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ក្នុងនោះរួមមាន៖ អនុបាតដើមទុនសរុប និងអនុបាតគ្របខ័ណ្ឌសន្ទនីយភាពមាន ២១,៨% និង ១៣៩,៣% រៀងគ្នា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនៅមានលទ្ធភាពស្វែងរកប្រាក់ចំណេញ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម ១% និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក ៥% ខណៈដែលអនុបាតឥណទានមិនដំណើរការមាន ៨,៩%។

ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបន្តរីកចម្រើន និងអនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមាន។

### ១.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ រួមមាន៖ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ។ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានចំនួន ១២,៤ ទ្រីលានរៀល (៣,១ ប៊ីលានដុល្លារអាមេរិក) ដែលរួមចំណែក ៣,១% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ទន្ទឹមនេះ ឥណទានអតិថិជនមានកំណើន ៨,៧% ដល់ ១១,៦ ទ្រីលានរៀល (២,៩ ប៊ីលានដុល្លារអាមេរិក)។

#### ១.២.២.១. ប្រតិបត្តិការនៃធនាគារឯកទេស

ធនាគារឯកទេសជាគ្រឹះស្ថានដែលអនុវត្តនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំង ៣ នៃអាជីវកម្មធនាគារ ដែលរួមមាន៖ ១/-ផ្តល់ឥណទាន ២/-ទទួលប្រាក់បញ្ញើ និង ៣/-ដាក់ឱ្យប្រើប្រាស់នូវមធ្យោបាយទូទាត់ ឬអនុវត្តតែផ្នែកមួយនៃសកម្មភាពទាំង ៣ នេះ ដោយបច្ចុប្បន្ន ធនាគារឯកទេសទាំងអស់ផ្តល់តែសេវាឥណទានប៉ុណ្ណោះ។ ទ្រព្យសកម្មរបស់ធនាគារឯកទេសបានថយចុះ ១,៩%ដល់ ២,៦ ទ្រីលានរៀល

(៦៥៨,៥ លានដុល្លារអាមេរិក) ដែលរួមចំណែក ០,៧% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ មូលនិធិភាគទុនិកបានធ្លាក់ចុះ ២,៣% ដល់ ១,១ ទ្រីលានរៀល (២៧២,១ លានដុល្លារអាមេរិក)។

ក្រាហ្វ ១៣៖ ធនាគារឯកទេស - ទ្រព្យសកម្ម និងកំណើន




ក្រាហ្វ ១៤៖ ធនាគារឯកទេស - ឥណទានអតិថិជន និងកំណើន




ឥណទានអតិថិជនរបស់ធនាគារឯកទេសបានកើនឡើង ៤,៧% ដល់ ២,៤ ទ្រីលានរៀល (៥៨៩,៦ លានដុល្លារអាមេរិក)។ ឥណទាននេះ បានរួមចំណែក ០,៩% នៃឥណទានសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា និងត្រូវបានផ្តល់ដល់វិស័យសំខាន់ៗក្នុងសកម្មភាពសេដ្ឋកិច្ច រួមមាន៖ សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ៧៤,៣% សកម្មភាពផ្នែកអចលនទ្រព្យ ១២,៩% អាជីវកម្មលក់រាយ ២,៧% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ១,៩% អាជីវកម្មលក់ដុំ ១,៥% កម្មន្តសាលកម្ម ១,៥% សំណង់ ១,៥% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ១% ការដឹកជញ្ជូននិងការស្តុកទុក ០,៥% និងឥណទានផ្សេងៗ ២,២%។

ក្រាហ្វ ១៥៖ ធនាគារឯកទេស - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច




ទន្ទឹមនេះ អត្រាការប្រាក់ជាមធ្យមលើឥណទានអ្នកប្រើប្រាស់ជាប្រាក់រៀល បានថយចុះពី ១៣,៤% ក្នុងឆ្នាំ២០២៤ ដល់ ៩% ក្នុងឆ្នាំ២០២៥ ខណៈដែលអត្រាការប្រាក់ឥណទានអ្នកប្រើប្រាស់ជាដុល្លារអាមេរិក ថយចុះពី ១២,៧% ក្នុងឆ្នាំ២០២៤ ទៅ ១១,៩% ក្នុងឆ្នាំ២០២៥។

ក្រាហ្វ ១៦៖ ធនាគារឯកទេស - អត្រាការប្រាក់មធ្យមលើឥណទាន




អនុបាតឥណទានមិនដំណើរការរបស់ធនាគារឯកទេសបានថយចុះដល់ ១៣,២% ពី ១៣,៩% នាឆ្នាំ២០២៤។ ធនាគារឯកទេសមានលទ្ធភាពទទួលបានប្រាក់ចំណេញឡើងវិញ ធៀបនឹងឆ្នាំមុន នាំឱ្យអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក កើនដល់ ១,៩% និង ៤,៧ % រៀងគ្នា។ បន្ថែមពីនេះទៀត ធនាគារឯកទេសនៅរក្សាបានអនុបាតសាធនភាព ៣៥,៤% លើសកម្រិតកំណត់អប្បបរមា ដែលតម្រូវដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ១៧៖ ធនាគារឯកទេស - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ




## ១.២.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានកំណើន ៧,៤% ដល់ ៨,៥ ទ្រីលានរៀល (២,១ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនមានកំណើន ១២,៨% ដល់ ៨ ទ្រីលានរៀល (២ ប៊ីលានដុល្លារអាមេរិក)។ បើប្រៀបធៀបទ្រព្យសកម្ម និងឥណទានអតិថិជនក្នុងប្រព័ន្ធធនាគារនៅកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានរួមចំណែក ២,១% និង ៣,១% រៀងគ្នា។

ក្រាហ្វ ១៨៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន




ក្រាហ្វ ១៩៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - កំណើនឥណទានអតិថិជន




ឥណទានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ បន្តចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងត្រូវបានផ្តល់ដល់វិស័យសំខាន់ៗក្នុងសកម្មភាពសេដ្ឋកិច្ច រួមមាន៖ សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ៤៧,៥% សកម្មភាពផ្នែកអចលនទ្រព្យ ៨,៥% សំណង់ ៦,៨% កម្មន្តសាលកម្ម ៥% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៤,៩% អាជីវកម្មលក់រាយ ៤,១% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៤,៤% ការដឹកជញ្ជូននិងការស្តុកទុក ៣,៨% អាជីវកម្មលក់ដុំ ១,៦% និងឥណទានផ្សេងៗ ១៣,៤%។

ក្រាហ្វ ២០៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ឥណទានតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច




អនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានថយចុះដល់ ១៤,៨% ពី ១៥,៤% នាឆ្នាំ២០២៤។ គ្រឹះស្ថានទាំងនេះមានលទ្ធភាពទទួលបានប្រាក់ចំណេញឡើងវិញធៀបនឹងឆ្នាំមុន នាំឱ្យអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកបានកើនដល់ ១,៨% និង ៥,៥% រៀងគ្នា។

ទោះយ៉ាងនេះក្តី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើនៅរក្សាបានអនុបាតសាធនភាពមាន ៣០% លើសកម្រិតកំណត់អប្បបរមាដែលកំណត់ដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ២១៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ




## ១.២.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មានចំនួន ១,៣ ទ្រីលានរៀល (៣១៧,៩ លានដុល្លារអាមេរិក) ដែលរួមចំណែក ០,៣% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានបន្តរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការបង្កើតលទ្ធភាពដល់អតិថិជន ជាពិសេសសហគ្រាសធុនតូចនិងមធ្យម ក្នុងការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដូចជា៖ សេវាភតិសន្យាហិរញ្ញវត្ថុលើម៉ូតូ រថយន្ត គ្រឿងយន្តកសិកម្មនិងសំណង់ និងគ្រឿងអេឡិចត្រូនិក ជាដើម។

តារាង ៣ ៖ សូចនាករសំខាន់ៗរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ

| សូចនាករ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|---|
| ចំនួនគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ | ១៧ | ១៦ | ១៦ | ១៣ | ១២ |
| ទ្រព្យសកម្មសរុប (គិតជាទ្រីលានរៀល) | ១,៨ | ២ | ២ | ១,៤ | ១,៣ |
| ភតិសន្យាហិរញ្ញវត្ថុសរុប (គិតជាទ្រីលានរៀល) | ១,៦ | ១,៨ | ១,៧ | ១,២ | ១,២ |
| មូលនិធិផ្ទាល់សុទ្ធ (គិតជាទ្រីលានរៀល) | ០,៦ | ០,៦ | ០,៦ | ០,៥ | ០,៥ |
| ចំនួនគណនីអតិថិជន | ១០៥.៨១១ | ៩៦.២៩១ | ៩០.៣៨២ | ៥១.៣០៧ | ៤៤.៦៨២ |
| អនុបាតភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ | ៥,១% | ៣,៨% | ៥,១% | ៨,៧% | ៤,៩% |

សមតុល្យភតិសន្យាហិរញ្ញវត្ថុចំនួន ១,២ ទ្រីលានរៀល (២៩២,៣ លានដុល្លារអាមេរិក) ត្រូវបានប្រើប្រាស់ដោយអតិថិជន ដែលមានគណនីសរុបចំនួន ៤៤.៦៨២ គណនី និងត្រូវបានបែងចែកទៅវិស័យចម្បងៗមួយចំនួន រួមមាន៖ កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៣២,១% សកម្មភាពគ្រួសារ

ជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ២៤,៦% អាជីវកម្មលក់រាយ ៤,៨% សំណង់ ៤,៤% អាជីវកម្មលក់ដុំ ២,៤% ការដឹកជញ្ជូននិងការស្តុកទុក ១,៨% កម្មន្តសាលកម្ម ១,១% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ១% សកម្មភាពផ្នែកអចលនទ្រព្យ ០,៩% និងឥណទានផ្សេងៗ ២៦,៩%។

ក្រាហ្វ ២២៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ - ភតិសន្យាហិរញ្ញវត្ថុតាមវិស័យ ស្ថាប័ន និងសកម្មភាពសេដ្ឋកិច្ច




អនុបាតភតិសន្យាហិរញ្ញវត្ថុមិនដំណើរការរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានថយចុះដល់ ៤,៩% ពី ៨,៧% នាឆ្នាំ២០២៤។ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមានលទ្ធភាពទទួលបានប្រាក់ចំណេញឡើងវិញធៀបនឹងឆ្នាំមុន នាំឱ្យអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកបានកើនដល់ ២,៨% និង ៧,១% រៀងគ្នា។ ទន្ទឹមនេះ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុនៅរក្សាបានអនុបាតសាធនភាពមាន ៣៧,៣% លើសកម្រិតកំណត់អប្បបរមាដែលតម្រូវដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ២៣៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ - អនុបាតប្រាក់ចំណេញនិងភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ




## ១.២.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទ បានបន្តចូលរួមផ្តល់ឥណទានខ្នាតតូច និងតូចបំផុត ជូនដល់ប្រជាជនដែលមានប្រាក់ចំណូលទាប ក្នុងទិសដៅទ្រទ្រង់ការប្រកបអាជីវកម្មលក្ខណៈគ្រួសារ ដើម្បីលើកកម្ពស់

ជីវភាពរស់នៅ។ ទ្រព្យសកម្មរបស់គ្រឹះស្ថានឥណទានជនបទមានចំនួន ២៨១,៨ ប៊ីលានរៀល (៧០,២ លានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនមានចំនួន ២៣៤,១ ប៊ីលានរៀល (៥៨,៣ លានដុល្លារអាមេរិក) ដោយផ្តល់ដល់អតិថិជនសរុបចំនួន ៩៧.១៩៦ អតិថិជន តាមរយៈបណ្តាញប្រតិបត្តិការនៅទូទាំងប្រទេស និងមានបុគ្គលិកបម្រើការចំនួន ២.០៩៧ នាក់។ ឥណទានត្រូវបានបែងចែកទៅកាន់វិស័យផ្សេងៗ រួមមាន៖ កសិកម្ម ២៨% គ្រួសារ ២៤,៦% ពាណិជ្ជកម្ម ២១,៣% សេវាកម្ម ១០,៤% សំណង់ ៤,៩% ដឹកជញ្ជូន ១,២% និងផ្សេងៗ ៩,៦%។

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានបន្តខិតខំយ៉ាងយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានឥណទានជនបទ និងមានវិធានការជាបន្តបន្ទាប់ សំដៅធានាការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងការធ្វើប្រតិបត្តិការអាជីវកម្ម ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រឹះស្ថានឥណទានជនបទ ដើម្បីការពារផលប្រយោជន៍របស់អតិថិជន។

ជារួម កំណើនឥណទាន និងលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានភាពប្រសើរជាងឆ្នាំមុន។ គ្រឹះស្ថានរក្សាបាននូវកម្រិតដើមទុនរឹងមាំ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតសាធនភាព លើសពីកម្រិតកំណត់អប្បបរមាដែលតម្រូវដោយបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមាន។

## ១.២.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ

ទីផ្សារអចលនវត្ថុក្នុងប្រទេសកម្ពុជាបានងាកចេញពីគម្រោងសាងសង់អចលនវត្ថុបែបប្រណិតទៅគម្រោងលំនៅឋានកម្រិតមធ្យម និងមានតម្លៃសមរម្យ សម្រាប់អតិថិជនគោលដៅដែលភាគច្រើនជាប្រជាជនក្នុងស្រុក។ វិស័យអចលនទ្រព្យនៅតែបន្តដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ច និងមានភាពពាក់ព័ន្ធយ៉ាងជិតស្និតជាមួយប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដល់គម្រោងសាងសង់និងអភិវឌ្ឍន៍អចលនវត្ថុនានា។ ឥណទានចំពោះវិស័យអចលនទ្រព្យ សំដៅដល់ការផ្តល់ឥណទានទៅសកម្មភាពអចលនទ្រព្យ (រួមបញ្ចូលទាំងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន) និងសំណង់ ដែលមានកំណើនសរុប ៦,៣%។ ចំណែកទីផ្សារឥណទាននៃវិស័យអចលនទ្រព្យស្មើនឹង ៣១,៩% នៃសំពៀតឥណទានសរុបរបស់ប្រព័ន្ធធនាគារ ដោយក្នុងនោះមានសកម្មភាពអចលនទ្រព្យ ២១,៨% (ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ៩,៨%) និងសំណង់ ១០,១%។

## ១.២.៤. ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ

វិស័យកសិកម្ម ជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើតឱកាសការងារ បង្កើនប្រាក់ចំណូល ធានាសន្តិសុខស្បៀងនៅក្នុងប្រទេសនិងការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ។ ប្រព័ន្ធធនាគារនៅកម្ពុជា បានចូលរួមចំណែកផ្តល់ឥណទានទៅវិស័យកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ សរុបចំនួន ២៣,៨ ទ្រីលាន

រៀល (៥,៩ ប៊ីលានដុល្លារអាមេរិក) ឬ ៩,៣% នៃសមតុល្យឥណទានអតិថិជនសរុបនៅក្នុងប្រព័ន្ធធនាគារ។ ធនាគារពាណិជ្ជ បានចូលរួមចំណែកក្នុងការផ្តល់ឥណទានទៅវិស័យនេះ ច្រើនជាងគេ ៨១,៦% បន្ទាប់មកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១៥,៣% ខណៈដែលធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានចូលរួមចំណែក ០,១% ១,៦% និង ១,៤% រៀងគ្នា។

ក្រាហ្វ ២៤ ៖ ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ក្នុងប្រព័ន្ធធនាគារនៅកម្ពុជា




សមតុល្យឥណទានសរុបទៅវិស័យកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទខាងលើ ត្រូវបានបែងចែកទៅកាន់ការដាំដុះដំណាំកសិផល ៨២,១% ការចិញ្ចឹមសត្វ ១៣,៧% រុក្ខាប្រម៉ាញ់ ២,២% និងនេសាទនិងវារីវប្បកម្ម ២%។

ក្រាហ្វ ២៥ ៖ ចំណែកទីផ្សារឥណទានទៅដំណាំកសិផល




តាមរយៈចំណែកទីផ្សារឥណទានច្រើនជាងគេ ៨២,១% នៃឥណទានសរុបទៅវិស័យកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ការដាំដុះដំណាំកសិផលបានទាញយកសមតុល្យឥណទានសរុបចំនួន ១៩,៦ ទ្រីលានរៀល (៤,៩ ប៊ីលានដុល្លារអាមេរិក)។ ឥណទានសម្រាប់ដំណាំកសិផល ដូចជាៈ វិស័យស្រូវអង្ករដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត

មានចំណែកទីផ្សារឥណទាន ៣៩,៥% ៨,៣% និង ៥៣,២% រៀងគ្នា។ វិស័យស្រូវ-អង្ករ បានស្រូបយកសមតុល្យឥណទានសរុបចំនួន ៧,៥ ទ្រីលានរៀល (១,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ ផលិតកម្មស្រូវ ៥,៧ ទ្រីលានរៀល (១,៤ ប៊ីលានដុល្លារអាមេរិក) ម៉ាស៊ីនកិនស្រូវ ១ ទ្រីលានរៀល (២៤៩,៩ លានដុល្លារអាមេរិក) និងការនាំចេញស្រូវ-អង្ករ ០,៨ ទ្រីលានរៀល (១៨៧,៣ លានដុល្លារអាមេរិក)។ ជារួមប្រព័ន្ធធនាគារកម្ពុជា បានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រវិស័យស្រូវ-អង្ករ ដែលជាសសរស្តម្ភមួយដ៏មានសក្តានុពលរបស់ប្រទេសកម្ពុជា ក្នុងការទ្រទ្រង់សន្តិសុខស្បៀង និងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការពង្រីកឱកាសពាណិជ្ជកម្មទៅក្នុងតំបន់និងឆាកអន្តរជាតិ។

ក្រាហ្វ ២៦ ៖ ចំណែកទីផ្សារឥណទានទៅវិស័យស្រូវ-អង្ករ




## ១.២.៥. ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម

សហគ្រាសធុនមីក្រូ តូច និងមធ្យម គឺជាឆ្អឹងខ្នងនៃសង្គម-សេដ្ឋកិច្ចជាតិ ដែលបានដើរតួនាទីយ៉ាងសកម្មនិងសំខាន់ក្នុងការចូលរួមចំណែកបង្កើតមុខរបរនិងឱកាសការងារ បង្កើនប្រាក់ចំណូល និងពង្រីកពពិធកម្មសេដ្ឋកិច្ចជាតិ។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់អំពីតួនាទី និងសក្តានុពលដ៏ធំធេងរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាបានភាពធន់នៃសេដ្ឋកិច្ចកម្ពុជា។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងធនាគារឯកទេស បានផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម កើនឡើង ១០,៨% ពី ៧៩,៧ ទ្រីលានរៀល (១៩,៨ ប៊ីលានដុល្លារអាមេរិក) ដែលមាន ៨១៩.៨១៥ អតិថិជន ក្នុងឆ្នាំ២០២៤ ដល់ ៨៨,៣ ទ្រីលានរៀល (២២ ប៊ីលានដុល្លារអាមេរិក) ដែលមាន ១.២៤៨.៦៥៩ អតិថិជន ក្នុងឆ្នាំ២០២៥។

## ១.២.៦. ឥណទាន និងប្រាក់បញ្ញើអតិថិជន នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមបណ្តារាជធានី-ខេត្ត

សមតុល្យឥណទាន និងប្រាក់បញ្ញើអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មានចំនួនសរុប ២៤៤ ទ្រីលានរៀល (៦០,៨ ប៊ីលានដុល្លារអាមេរិក) និង ២៥៧,៦ ទ្រីលានរៀល (៦៤,២ ប៊ីលានដុល្លារអាមេរិក) រៀងគ្នា កើនឡើង ៥,៣% សម្រាប់ឥណទាន និងកើនឡើង ១២,៤% សម្រាប់ប្រាក់បញ្ញើ។ ចំនួនអ្នកខ្ចីប្រាក់បានកើនឡើងដល់ ៤.២៥៥.៨៤០ អតិថិជន (៣.៦៤២.០៨២ គណនី)

ខណៈដែលចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនឡើងដល់ ១៩.៥០៦.៨៣៥អតិថិជន (៣១.៨៣២.១២០ គណនី)។ ការកើនឡើងនៃសមតុល្យឥណទាន និងប្រាក់បញ្ញើអតិថិជន ក៏ដូចជាចំនួនគណនីឥណទាន និងប្រាក់បញ្ញើអតិថិជន បានឆ្លុះបញ្ចាំងអំពីជំនឿទុកចិត្តរបស់សាធារណជននិងអ្នកវិនិយោគិនមកលើប្រព័ន្ធធនាគារនៅកម្ពុជា ព្រមទាំងបានបង្ហាញអំពីផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដ៏សំបូរបែបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបម្រើតម្រូវការជូនអតិថិជន។

សមតុល្យឥណទានអតិថិជនខាងលើ ត្រូវបានផ្តល់ជូនអតិថិននៅក្នុងរាជធានីភ្នំពេញច្រើនជាងគេដែលមាន ៥៧,១% នៃសមតុល្យឥណទានសរុប និងបន្ទាប់មកខេត្តកណ្តាល ៤,២% ខេត្តសៀមរាប ៣,៩% ខេត្តតាកែវ ៣,៥% ខេត្តកំពង់ស្ពឺ ៣,២% ខេត្តបាត់ដំបង ៣% និងបណ្តាខេត្តផ្សេងៗ ទៀតសរុប ២៥,១%។

ក្រាហ្វ ២៧ ៖ ចំណែកទីផ្សារឥណទានអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមបណ្តារាជធានី-ខេត្ត




ដោយឡែក ចំពោះប្រាក់បញ្ញើអតិថិជន រាជធានីភ្នំពេញមានសមតុល្យប្រាក់បញ្ញើច្រើនជាងគេ ៨០,៦% នៃសមតុល្យប្រាក់បញ្ញើអតិថិជនសរុប និងបន្ទាប់មកខេត្តព្រះសីហនុ ៣,៨% ខេត្តកណ្តាល ២,១% ខេត្តបន្ទាយមានជ័យ ១,៩% ខេត្តសៀមរាប ១,៨% ខេត្តបាត់ដំបង ១,៣% និងបណ្តាខេត្តផ្សេងៗទៀតសរុប ៨,៥%។

ក្រាហ្វ ២៨ ៖ ចំណែកទីផ្សារប្រាក់បញ្ញើអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមបណ្ដារាជធានី-ខេត្ត




## ១.២.៧. ប្រាក់បញ្ញើតាមប្រភេទអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ក្រាហ្វ ២៩ ៖ ចំណែកទីផ្សារប្រាក់បញ្ញើអតិថិជនតាមប្រភេទអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ




ប្រាក់បញ្ញើអតិថិជន (មិនរួមបញ្ចូលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) បានកើនឡើង ១២,៤% ពី ២២៩,២ ទ្រីលានរៀល (៥៦,៩ ប៊ីលានដុល្លារអាមេរិក) ឆ្នាំ២០២៤ ដល់ ២៥៧,៦ ទ្រីលានរៀល (៦៤,២ ប៊ីលានដុល្លារអាមេរិក) ឆ្នាំ២០២៥។ ចំណែកទីផ្សារប្រាក់បញ្ញើខាងលើនេះ ត្រូវបានបែងចែកតាមប្រភេទអតិថិជន រួមមាន៖ រូបវន្តបុគ្គល ៧៣% សហគ្រាសអាជីវកម្ម ១៦,៤% រដ្ឋាភិបាលនិងសហគ្រាសរដ្ឋ ៥,២% និងផ្សេងៗ ៥,៤%។

### ១.២.៨. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

គ្រឹះស្ថានទទួលបានអាជ្ញាបណ្ណផ្តល់សេវាទូទាត់សងប្រាក់មានចំនួន ៣០ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ៣ ផ្សេងទៀត បានទទួលលិខិតអនុញ្ញាតផ្តល់សេវាទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា។ ប្រតិបត្តិការរបស់គ្រឹះស្ថានទាំងនេះ បានផ្លាស់ប្តូររបៀបនៃការទូទាត់របស់ប្រជាពលរដ្ឋ ជំនួសឱ្យការប្រើប្រាស់សាច់ប្រាក់ និងបានរួមចំណែកក្នុងការបង្កើនកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ គិតត្រឹមឆ្នាំ២០២៥ មានអតិថិជនដែលបានចុះឈ្មោះបង្កើតគណនីកាបូបអេឡិចត្រូនិកសរុប ១៧,៩ លានគណនី ពោលគឺថយចុះ ១៣,៩% ហើយចំនួនប្រតិបត្តិការនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិកបានកើនឡើងដល់ ៨០,៨% ដល់ ២,២ ប៊ីលានប្រតិបត្តិការ និងទំហំប្រតិបត្តិការសរុបបានកើនឡើង ៩៦,៥% ដល់ ១៧០ ប៊ីលានដុល្លារអាមេរិក ៣,៤ ដង នៃផ.ស.ស។

### ១.២.៩. អាជីវកម្មប្តូរប្រាក់

អាជីវកម្មប្តូរប្រាក់សរុបទូទាំងប្រទេសមានចំនួន ៣.៣៩៣ ក្នុងនោះ អាជ្ញាបណ្ណប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ៣៨ (រាជធានីភ្នំពេញចំនួន ៣៣ និងខេត្តចំនួន ៥) និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ៣.៣៥៥ (រាជធានីភ្នំពេញចំនួន ៥៨ និងខេត្តចំនួន ៣.២៩៧)។ ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានចេញអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ថ្មីសរុបចំនួន ១៣ ក្នុងនោះមានអាជ្ញាបណ្ណចំនួន ២ និងលិខិតអនុញ្ញាតចំនួន ១១។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានបញ្ចប់អាជ្ញាបណ្ណចំនួន ៤ និងលិខិតអនុញ្ញាតចំនួន ២។

ក្រាហ្វ ៣០៖ អាជីវកម្មប្តូរប្រាក់ - ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត






ក្រាហ្វ ៣១៖ អាជីវកម្មប្ដូរប្រាក់ - ចំនួនលិខិតអនុញ្ញាតនៅតាមបណ្ដាខេត្ត




## ១.៣. ប្រតិបត្តិការនៃទីផ្សារអន្តរធនាគារ

ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវឧបករណ៍សំខាន់ៗ ដូចជា មូលបត្រអាចជួញដូរបាន ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា និងឧបករណ៍ផ្ដល់សន្ទនីយភាពរយៈពេលខ្លី សំដៅចូលរួមអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា។ ទំហំមូលបត្រអាចជួញដូរបានជាប្រាក់រៀលដែលបានបោះផ្សាយកើនឡើង ៨៤,៣% ដល់ ៩៩,៣ ទ្រីលានរៀល និងមូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិកកើនឡើង ៥,៨% ដល់ ៤ ប៊ីលានដុល្លារអាមេរិក។ ការដេញថ្លៃប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា ត្រូវបានធ្វើឡើងសរុបចំនួន ៤៨ លើក ដោយបានផ្ដល់សន្ទនីយភាពសរុបចំនួន ៣,៧ ទ្រីលានរៀល (៩២៥,៨ លានដុល្លារអាមេរិក) ដែលថយចុះ ០,១៥% បើធៀបនឹងឆ្នាំ២០២៤។ គួរកត់សម្គាល់ថា ការថយចុះនូវប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានានេះគឺដោយសារកម្រិតខ្ពស់នៃសន្ទនីយភាពជាប្រាក់រៀលក្នុងប្រព័ន្ធធនាគារ ស្របពេលកំណើនឥណទានបានថយល្បឿនផងដែរ។ ចំណែកប្រតិបត្តិការផ្ដល់សន្ទនីយភាពរយៈពេលខ្លី បានជួយបំពេញតម្រូវការសន្ទនីយភាពជាប្រាក់រៀល (ផ្ដល់ជូនភ្លាមៗនៅក្នុងថ្ងៃ និងអាចបន្តបានដោយគ្មានការកំណត់ឥណប្រតិទាន) ដោយក្នុងឆ្នាំ២០២៥ ប្រតិបត្តិការផ្ដល់សន្ទនីយភាពរយៈពេលខ្លីចំនួន ១,៧ ប៊ីលានរៀល ត្រូវបានផ្ដល់ឱ្យគ្រឹះស្ថានធនាគារចំនួន ២ ក្នុងអត្រាការប្រាក់ ៥%។ ធនាគារជាតិនៃកម្ពុជា បានផ្ដល់ការអនុញ្ញាតដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៩ ប្រើប្រាស់ប្រតិបត្តិការផ្ដល់សន្ទនីយភាពរយៈពេលខ្លីដែលធានាដោយមូលបត្រអាចជួញដូរបាន និង/ឬ មូលបត្ររដ្ឋ។ នៅក្នុងឆ្នាំ២០២៥ អត្រាការប្រាក់ប្រតិបត្តិការផ្ដល់សន្ទនីយភាពរយៈពេលខ្លីត្រូវបានបន្ថយពី ៥,៥% មក ៥% ដែលមានលក្ខណៈល្អជាងអត្រាឥណទានវិបារូបន៍ជាដុល្លារអាមេរិក ៦%។

## ២. ការវិវឌ្ឍនៃក្របខ័ណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិ

### ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជា បានដាក់ចេញបទប្បញ្ញត្តិថ្មី និងកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់ជាបន្តបន្ទាប់ ដើម្បីធានាវឌ្ឍនភាពនៃប្រព័ន្ធធនាគារ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ ក្នុងឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញប្រកាសស្ដីពី វិធានការបុរេសកម្មចំពោះ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងកែសម្រួលប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំប្រកាស និងសេចក្តីណែនាំមួយចំនួន រួមមាន៖ ១/-ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ២/-ប្រកាសស្តីពី លក្ខខណ្ឌផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាតចំពោះគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មគ្រីបតូ ៣/-ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចាំបាច់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤/-ប្រកាសស្តីពី អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥/-ប្រកាសស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្ម និង ៦/-ប្រកាសស្តីពី ក្របខ័ណ្ឌអនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំបទប្បញ្ញត្តិឱ្យស្របតាមការវិវឌ្ឍនៃប្រព័ន្ធហិរញ្ញវត្ថុ និងស្តង់ដាអន្តរជាតិ ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ដូចជា៖ ១/-កិច្ចសហប្រតិបត្តិការជាមួយនិយ័តករមូលបត្រកម្ពុជានិងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី លើកិច្ចការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ២/-កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មកូរ៉េពាក់ព័ន្ធនឹងការដោះស្រាយឥណទានមិនដំណើរការ និង ៣/-កិច្ចសហប្រតិបត្តិការជាមួយជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ តាមរយៈការផ្តល់ជំនួយផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

គិតត្រឹមឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ១២ លើក និងវគ្គបណ្តុះបណ្តាលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៧ លើក។ វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងវិស័យធនាគារ ព្រមទាំងផ្សព្វផ្សាយបទប្បញ្ញត្តិថ្មី និងពង្រឹងការយល់ដឹងបទប្បញ្ញត្តិដែលមានស្រាប់។

## ២.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ២.២.១. សកម្មភាពនៃការត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងតាមដាន និងត្រួតពិនិត្យជាប្រចាំចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។

#### ២.២.១.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តតាមដានជាប្រចាំលើស្ថានភាពទូទៅ ភាពធន់ និងស្ថិរភាពនៃប្រព័ន្ធធនាគារទាំងមូល តាមរយៈការអនុវត្តក្របខណ្ឌនៃការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ដោយអនុលោមតាមវិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃស្រេប។ ទន្ទឹមនេះ ធនាគារជាតិ

នៃកម្ពុជា បានរួមបញ្ចូលការធ្វើស្ត្រេសតេស្ត ដើម្បីវាយតម្លៃនិងវាស់វែងលើភាពធន់នៃសន្ទនីយភាព និងភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ព្រមទាំងត្រួតពិនិត្យលើគុណភាពឥណទាន អនុបាតឥណទានមិនដំណើរការ ឥណទានរៀបចំឡើងវិញ លទ្ធភាពស្វែងរកប្រាក់ចំណេញ ព្រមទាំងការតាមដានអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិជាដើម។ ធនាគារជាតិនៃកម្ពុជា បានជួបប្រជុំជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានជាបន្តបន្ទាប់ ដើម្បីពិភាក្សាអំពីស្ថានភាពនៃអាជីវកម្ម គុណភាពឥណទាន ការដោះស្រាយឥណទានមិនដំណើរការ យុទ្ធសាស្ត្រអាជីវកម្ម និងស្ថានភាពឥណទានចំពោះវិស័យអចលនទ្រព្យជាដើម។ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែង ចំពោះគ្រឹះស្ថាន ចំនួន ៨ ដោយបានផ្តោតលើការវាយតម្លៃ៖ ១/-គុណភាពឥណទាន រួមទាំង ការធ្វើចំណាត់ថ្នាក់ឥណទាន ការធ្វើសំវិធានធនលើអ៊ីមភែរមិន និងការរៀបចំឥណទានឡើងវិញ ២/-អភិបាលកិច្ច ៣/-ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការ ៤/-ការត្រួតពិនិត្យលើការអនុវត្តតាមអនុសាសន៍ដែលបានដាក់ចេញ និង ៥/-ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាលទ្ធផលនៃការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង គ្រឹះស្ថានភាគច្រើនបន្តរក្សាបាននូវភាពធន់នៃដើមទុននិងភាពគ្រប់គ្រាន់នៃសន្ទនីយភាព មានអភិបាលកិច្ចល្អ ការគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួនក៏នៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុងនិងអភិបាលកិច្ច ការប្រឈមនឹងកំណើននៃឥណទានមិនដំណើរការ ការថយចុះនូវលទ្ធភាពរកប្រាក់ចំណេញ ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការនៅមានកម្រិត និងការមិនទាន់អនុវត្តបានពេញលេញតាមអនុសាសន៍ ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងតាមដានជាប្រចាំ និងដាក់ចេញនូវអនុសាសន៍និងវិធានការកែតម្រូវបន្ថែមទៀត។

### ២.២.១.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងតាមដាន និងវាយតម្លៃពីស្ថានភាពហានិភ័យ និងភាពធន់នៃស្ថានភាពហិរញ្ញវត្ថុជាប្រចាំគ្រាចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន តាមរយៈការអនុវត្តការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង។ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារជាតិនៃកម្ពុជា អនុវត្តវិធីសាស្ត្រនៃការត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត និងវិធីសាស្ត្រ CAMEL-HIS ដោយផ្តោតលើការវាយតម្លៃ៖ ១/-ភាពគ្រប់គ្រាន់នៃដើមទុន ២/-គុណភាពទ្រព្យសកម្ម ៣/-អភិបាលកិច្ច ៤/-លទ្ធភាពរកប្រាក់ចំណេញ និង ៥/-គុណវុឌ្ឍិរបស់បុគ្គលិក ជាដើម។

ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែង លើគ្រឹះស្ថានចំនួន ៤៧ ក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨ ការិយាល័យតំណាងចំនួន ១ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ២ និងគ្រឹះស្ថានឥណទានជនបទចំនួន ៣៦។ វិសាលភាពនៃការត្រួតពិនិត្យដល់ទីកន្លែង គឺផ្តោតសំខាន់ចំពោះការវាយតម្លៃលើការធ្វើចំណាត់ថ្នាក់ឥណទាននិងការធ្វើសំវិធានធនលើអ៊ីមភែរមិន និងអភិបាលកិច្ច។

ជាលទ្ធផល គ្រឹះស្ថានភាគច្រើនរក្សាបាននូវដើមទុនគ្រប់គ្រាន់ និងបន្តពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន តាមរយៈការយកចិត្តទុកដាក់បន្ថែមក្នុងការបញ្ចេញឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ធនាគារជាតិនៃកម្ពុជា ក៏បានចាត់វិធានការនានា ដែលរួមមាន ការផ្តល់ជាអនុសាសន៍កែតម្រូវ និងការអនុវត្តវិធានការរដ្ឋបាលមួយចំនួន ចំពោះគ្រឹះស្ថានដែលមិនបានអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ។

### ២.២.១.៣. ការត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

បច្ចុប្បន្ន បច្ចេកវិទ្យាព័ត៌មានវិទ្យាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សដូចជា សេវាក្លោដ ទិន្នន័យធំ ប្លុកឆេន បញ្ញាសិប្បនិម្មិត និង Quantum Computer។ ការរីកចម្រើននៃបច្ចេកវិទ្យាដ៏មានឥទ្ធិពលទាំងនេះបាននាំមកនូវឱកាសថ្មីៗដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងផ្តល់សេវាកម្មថ្មីៗជូនដល់អតិថិជន ប៉ុន្តែវាក៏បង្កប់នូវហានិភ័យដែលមិនអាចមើលរំលងបានដូចជា ការរាំងស្ទះដំណើរការប្រព័ន្ធ និងការគំរាមកំហែងសាយប័រ។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងកែសម្រួលសេចក្តីណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យស្របទៅតាមការវិវត្តនៃបច្ចេកវិទ្យា និងហានិភ័យដែលអាចកើតមានដោយបានពិគ្រោះយោបល់ជាមួយគ្រឹះស្ថានទាំងនោះ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន ២ លើក។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំកិច្ចពិភាក្សាជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពី សុវត្ថិភាពសាយប័រ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់សន្តិសុខសាយប័រ។ ក្នុងក្របខ័ណ្ឌត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារពាណិជ្ជចំនួន ៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ដោយផ្តោតទៅលើ អភិបាលកិច្ចលើប្រព័ន្ធព័ត៌មានវិទ្យា ប្រព័ន្ធធនាគារស្នូល សុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា ឧបទ្ទវហេតុព័ត៌មានវិទ្យា ការគ្រប់គ្រងការផ្លាស់ប្តូរ សេវាក្លោដ ប្លុកឆេន ផែនការនិរន្តរភាពធុរកិច្ចផែនការស្តារប្រព័ន្ធពីគ្រោះមហន្តរាយ និងការពិនិត្យឯកសារសវនកម្មព័ត៌មានវិទ្យា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានទទួលការរាយការណ៍អំពីឧបទ្ទវហេតុព័ត៌មានវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ជាលទ្ធផល គ្រឹះស្ថានទាំងនោះ បានអនុវត្តល្អនូវការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា បទដ្ឋានឧត្តមានុវត្តន៍ និងអនុលោមតាមសេចក្តីណែនាំ ស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប៉ុន្តែ គ្រឹះស្ថាននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីប្រើប្រាស់ ប្រព័ន្ធព័ត៌មានវិទ្យា ការគ្រប់គ្រងសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធធនាគារស្នូល ការតាមដានប្រតិបត្តិការជាមួយតតីយភាគីរបស់គ្រឹះស្ថាន ការពឹងផ្អែកលើសលប់លើក្រុមហ៊ុនផ្តល់សេវាក្លោដតែមួយ និងការខ្វះខាតការធ្វើតេស្តជ្រៀតចូលប្រព័ន្ធ ជាដើម ដែលទាមទារនូវការតាមដាន និងត្រួតពិនិត្យជាប្រចាំលើការអនុវត្តតាមអនុសាសន៍របស់ធនាគារជាតិនៃកម្ពុជា។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា

កំពុងអភិវឌ្ឍឧបករណ៍ត្រួតពិនិត្យសម្រាប់ការវាយតម្លៃលើស្ថានភាពរបស់គ្រឹះស្ថាន ដែលជាជំនួយដល់មន្ត្រីត្រួតពិនិត្យក្នុងការវិភាគ និងតាមដានហានិភ័យបច្ចេកវិទ្យានិងសាយប័រ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើទំនើបកម្មប្រព័ន្ធត្រួតពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យ និងការធ្វើស្វ័យប្រវត្តិកម្មការងារ ដូចជាប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ ប្រព័ន្ធវិភាគទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងលំហូរការងារជាដើម។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងប្រើប្រាស់ធនធានមនុស្សផ្ទៃក្នុង និងសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់បច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីសិក្សា កាលានុវត្តភាពនៃបច្ចេកវិទ្យាថ្មីៗផងដែរ។

## ២.២.២. ឥណទានរៀបចំឡើងវិញ

ក្នុងស្មារតីសាមគ្គីភាព មនុស្សធម៌ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលបន្ទុកដល់យោធិនដែលធ្វើប្រតិបត្តិការដោយផ្ទាល់ក្នុងសមរភូមិប្រយុទ្ធ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសេចក្តីណែនាំចំនួន ២ លើក គឺ លើកទី១ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ និងលើកទី២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ស្តីពី វិធានការជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានរៀបចំឥណទានឡើងវិញដល់អតិថិជនសរុបចំនួន ២០៧.៨៣០ គណនី និងមានសមតុល្យដក់សល់ចំនួន ៥,៦៥ ប៊ីលានដុល្លារអាមេរិក (ស្មើនឹង ៩% នៃឥណទានសរុប) ដែលក្នុងនោះឥណទានមិនដំណើរការមានចំនួន ១,៩១ ប៊ីលានដុល្លារអាមេរិក (ស្មើនឹង ៣៣,៨% នៃឥណទានរៀបចំឡើងវិញសរុប)។ ទន្ទឹមនេះ វិស័យសេដ្ឋកិច្ចធំៗមួយចំនួនដែលគ្រឹះស្ថានផ្តល់ការរៀបចំឥណទានឡើងវិញមានដូចជា៖ ១/-អាជីវកម្មលក់រាយ ១២% (០,២២ ប៊ីលានដុល្លារអាមេរិក) ២/-សកម្មភាពផ្នែកអចលនទ្រព្យ ៧,៩២% (១,០៨ ប៊ីលានដុល្លារអាមេរិក) ៣/-កសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ៨,៧៨% (០,០៥ ប៊ីលានដុល្លារអាមេរិក) ៤/-សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងផ្គត់ផ្គង់សេវាកម្មដែលមិនអាចញែកដាច់ពីគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ៦,២៧% (០,៤២ ប៊ីលានដុល្លាអាមេរិក) ៥/-អាជីវកម្មលក់ដុំ ៤,៥៤% (០,៤៤ ប៊ីលានដុល្លារអាមេរិក) និង ៦/-សំណង់ ៧,២២% (០,៤៥ ប៊ីលានដុល្លារអាមេរិក)។ ចំណែកឯគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានរៀបចំឥណទានឡើងវិញជូនអតិថិជនចំនួន ១.៥០៨ គណនី ជាមួយសមតុល្យសរុប ០,៦២ ប៊ីលានរៀល (១១,៤ លានដុល្លារអាមេរិក)។

## ២.៣. ហិរញ្ញវត្ថុប្រកបដោយចីរភាព

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល និងស្របតាមតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និងភាពធន់ដែលអាចទប់ទល់នឹងហានិភ័យពីការប្រែប្រួលអាកាសធាតុ ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់លើការ

លើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ដោយផ្អែកលើមូលដ្ឋានគោលនយោបាយ និងគំនិតផ្តួចផ្តើមជាតិពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្រ្តរយៈពេលវែងសម្រាប់អព្យាក្រឹតភាពកាបូនរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីអនុវត្តការងារនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតការិយាល័យហិរញ្ញវត្ថុប្រកបដោយចីរភាព និងរៀបចំឱ្យមានក្រុមការងារហិរញ្ញវត្ថុបៃតងអន្តរក្រសួង ដើម្បីផ្តល់យោបល់លើការរៀបចំបទប្បញ្ញត្តិ យុទ្ធសាស្រ្ត និងគោលនយោបាយ ព្រមទាំងកំណត់ទិសដៅអាទិភាពសម្រាប់ការកៀរគរហិរញ្ញវត្ថុបៃតង។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពមន្រ្តី និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅលើការងារនេះ។

បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអភិវឌ្ឍផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីជាមគ្គុទេសក៍ក្នុងការជំរុញវិស័យនេះដោយផ្តោតលើការលើកទឹកចិត្ត ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធ ការពង្រឹងសមត្ថភាព និងការកៀរគរមូលនិធិ។ ជាមួយគ្នានេះ ប្រព័ន្ធវដ្តករសាស្រ្ត ដែលជាប្រព័ន្ធចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ច ឬគម្រោងវិនិយោគ ក៏ត្រូវបានរៀបចំឡើងដើម្បីផ្តល់និយមន័យរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា និងដើម្បីទប់ស្កាត់ការអះអាងមិនពិតអំពីភាពបៃតង (Greenwashing)។ ធនាគារជាតិនៃកម្ពុជា បានចូលរួមយ៉ាងសកម្មជាសមាជិកនៃក្រុមការងារថ្នាក់តំបន់ ដូចជា ក្រុមប្រឹក្សាប្រព័ន្ធវដ្តករសាស្រ្តអាស៊ាន និងក្រុមការងារហិរញ្ញវត្ថុបៃតងនៃសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ។ ការចូលរួមនេះ បានជួយជម្រុញការរៀបចំប្រព័ន្ធវដ្តករសាស្រ្ត និងជួយពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ ដូចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យដើរស្របតាមស្តង់ដាតំបន់ និងសកលលោក។

## ប្រអប់ទី១

## យន្តការឆ្លើយតបទៅនឹងបញ្ជីទណ្ឌកម្មរបស់ការិយាល័យគ្រប់គ្រងទ្រព្យសកម្មបរទេស នៃ ក្រសួងហិរញ្ញវត្ថុសហរដ្ឋអាមេរិក

កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ សភាសហរដ្ឋអាមេរិកបានរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងការឆបោកតាមប្រព័ន្ធអនឡាញ ដោយស្នើដាក់ទណ្ឌកម្មដល់បុគ្គល និងក្រុមហ៊ុនពាក់ព័ន្ធមួយចំនួននៅកម្ពុជា ក្នុងនោះ ១/-លោក ចេន ហ្ស៊ី ២/-ក្រុមហ៊ុន ព្រីនស៍ហ្វូលឌីង គ្រុប និង ៣/-បុគ្គលពាក់ព័ន្ធមួយចំនួនទៀត ក៏ត្រូវបានបញ្ចូលក្នុងបញ្ជីឈ្មោះ នោះដែរ។ ការណ៍នេះ បានបង្កឱ្យមានផលប៉ះពាល់កេរ្តិ៍ឈ្មោះយ៉ាងធ្ងន់ធ្ងរមកលើធនាគារ ព្រីនស៍ ម.ក ព្រមទាំងប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងៗទៀតដែលកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជា។

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីប្រកាសព័ត៌មានជូនសាធារណជនបានជ្រាបពីស្ថានភាពធនាគារ ព្រីនស៍ ម.ក និងវិធានការណ៍នានាស្របតាមច្បាប់និងបទប្បញ្ញត្តិ ដើម្បីកាត់បន្ថយក្តីបារម្ភរបស់សាធារណជនជាម្ចាស់ប្រាក់បញ្ញើ។ បន្ថែមពីលើនេះ ធនាគារជាតិនៃកម្ពុជា បានបន្តតាមដានស្ថានភាពខាងលើយ៉ាងយកចិត្តទុកដាក់ជាទីបំផុត និងបានសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរពាក់ព័ន្ធ ក្នុងការចាត់វិធានការចាំបាច់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាបាននូវសុវត្ថិភាពនៃប្រាក់បញ្ញើរបស់អតិថិជន ស្ថិរភាពនិងជំនឿទុកចិត្តរបស់សាធារណជន និងអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិនានា ជាធរមាន។

បច្ចុប្បន្ន ធនាគារ ព្រីនស៍ ម.ក ត្រូវបានដាក់ឱ្យជម្រះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានតែងតាំងក្រុមហ៊ុនម៉ូរីសុនកាក់ អិមខេអេ អឌីត-អឺខោនធីង ឯ.ក ជាអ្នកជម្រះបញ្ជីធនាគារ។ ក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ធនាគារ ព្រីនស៍ ម.ក ត្រូវបានផ្អាកមិនឱ្យផ្តល់សេវាធនាគារថ្មីទៀតនោះទេ រួមទាំងការទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន។ ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងបន្តតាមដានយ៉ាងប្រុងប្រយ័ត្នខ្ពស់បំផុតលើការអនុវត្តរបស់អ្នកជម្រះបញ្ជីរបស់ធនាគារ ព្រីនស៍ ម.ក ដើម្បីធានាការពារផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើ ក៏ដូចជាអតិថិជននានា។

## ៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

### ៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

#### ៣.១.១. បច្ចេកវិទ្យាហិរញ្ញវត្ថុ

កម្រងសំណួរសម្រាប់ការវាយតម្លៃការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងរបាយការណ៍ប្រចាំខែ ស្តីពី "ឧបទ្ទវហេតុព័ត៌មានវិទ្យា" សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានដាក់ឱ្យអនុវត្ត និងតម្រូវឱ្យគ្រឹះស្ថានរាយការណ៍ជាប្រចាំគ្រា។ ដោយឡែក គោលការណ៍ណែនាំស្តីពី "ការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា" ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៩។ ស្របតាមការវិវត្តនៃបច្ចេកវិទ្យានិងហានិភ័យពាក់ព័ន្ធ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំ ស្តីពី "ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"។

ដើម្បីឱ្យការរៀបចំសេចក្តីណែនាំថ្មីនេះបានគ្រប់ជ្រុងជ្រោយ ធនាគារជាតិនៃកម្ពុជា ក៏បានរៀបចំសិក្ខាសាលាចំនួន ៤ លើក ក្នុងគោលបំណងពិនិត្យនិងពិភាក្សាលើការអនុវត្តសេចក្តីណែនាំឆ្នាំ២០១៩ និងប្រមូលធាតុចូលពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ដើម្បីធ្វើបច្ចុប្បន្នកម្មលើសេចក្តីណែនាំនេះ និងផ្សព្វផ្សាយពីចំណុចសំខាន់ៗដែលត្រូវកែលម្អនិងបន្ថែមថ្មី។ សេចក្តីណែនាំ ស្តីពី "ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" គ្រោងនឹងដាក់ឱ្យអនុវត្តក្នុងខែមករា ឆ្នាំ២០២៦។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានរៀបចំសិក្ខាសាលាស្តីពី "សុវត្ថិភាពសាយប័រចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ក្នុងគោលបំណងពិភាក្សានិងចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងសុវត្ថិភាពសាយប័រ សំដៅពង្រឹងសមត្ថភាពរបស់គ្រឹះស្ថានក្នុងការកាត់បន្ថយផលប៉ះពាល់ពីការគំរាមកំហែងផ្នែកសាយប័រ និងឆ្លើយតបទាន់ពេលវេលា។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតគំនិតផ្តួចផ្តើមលើការប្រមូលផ្តុំគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ចូលរួមក្នុងថ្នាល ឬបណ្តាញទំនាក់ទំនងរួមមួយ ដើម្បីសម្រួលនិងពន្លឿនការចែករំលែកព័ត៌មាន រវាងធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាន់តែមានប្រសិទ្ធភាព ដែលគំនិតផ្តួចផ្តើមនេះនឹងដាក់ឱ្យអនុវត្តនាពេលឆាប់ៗនេះ។

ក្នុងកិច្ចខិតខំប្រឹងប្រែងពង្រឹងការគ្រប់គ្រងសំណើសុំនិងឯកសារគាំទ្រនានារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NBC Portal ដែលប្រព័ន្ធនេះកំពុងស្ថិតក្នុងដំណាក់កាលសាកល្បង។ ជាមួយគ្នានេះ វគ្គបណ្តុះបណ្តាលស្តីពី "ការប្រើប្រាស់ប្រព័ន្ធ NBC Portal" ត្រូវបានរៀបចំជាបន្តបន្ទាប់ និងបានជ្រើសរើសគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនចូលរួមក្នុងគម្រោងសាកល្បងនេះ។

### ៣.១.២. ប្រព័ន្ធទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជា បានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាបន្តបន្ទាប់ ដោយរួមបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងមុខងារសំខាន់ៗ ដែលជួយសម្រួល និងលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់របស់អតិថិជនឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងប្រកបដោយទំនុកចិត្ត។ ប្រព័ន្ធទូទាត់សងប្រាក់កម្ពុជាបានប្រែក្លាយកម្ពុជាពីប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើសាច់ប្រាក់ ទៅជាប្រទេសដែលមានប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលដែលទទួលស្គាល់ដោយស្ថាប័នជាតិ និងអន្តរជាតិ។ សមិទ្ធផលដែលសម្រេចបាននេះ កើតចេញពីគំនិតផ្តួចផ្តើម និងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្រោមកិច្ចសហការយ៉ាងជិតស្និតជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាការចូលរួមពីសាធារណជនតាមរយៈជំនឿទុកចិត្ត និងការប្រើប្រាស់។

ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ច និងសង្គមឌីជីថល ប្រព័ន្ធទូទាត់សងប្រាក់ទាំងតម្លៃរាយនិងតម្លៃធំត្រូវបានធ្វើទំនើបកម្មជាលំដាប់ ដែលបានគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនិងសមាហរណកម្មប្រព័ន្ធទូទាត់នៅក្នុងតំបន់និងអន្តរជាតិ។ ជាក់ស្តែង ការដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម កាលពីពាក់កណ្តាលឆ្នាំ២០២៤ បានសម្រួលដល់សមាជិកនិងអតិថិជនក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថាន កាន់តែងាយស្រួល សុវត្ថិភាព និងឆាប់រហ័ស ព្រមទាំងបានរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងបរិយាបន្នហិរញ្ញវត្ថុ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំដាក់ចេញវិធាននិងនីតិវិធីនៃប្រព័ន្ធទូទាត់សងប្រាក់រួម ព្រមទាំងឯកសារគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដំណើរការប្រព័ន្ធ និងទុកជាចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិកអនុវត្ត ក៏ដូចជាកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធ និងទទួលបានទំនុកចិត្តពីសាធារណជន។

សេវាទូទាត់សងប្រាក់បានវិវត្តទៅមុខគួរឱ្យកត់សម្គាល់ និងបន្តចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាហិរញ្ញវត្ថុដ៏សម្បូរបែប តាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាចំណែកមួយជំរុញឱ្យមានការប្រកួតប្រជែង និងការពង្រីកសេវាទូទាត់សងប្រាក់ និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិកកាន់តែទូលំទូលាយថែមទៀត។ មធ្យោបាយអេឡិចត្រូនិកទាំងនេះ បានផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការបែបឌីជីថលដោយខ្លួនឯងបានតាមរយៈ សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងសេវាទូទាត់ចល័ត ជាពិសេស ការទូទាត់ប្រតិបត្តិការតាមយូអរកូដ ដែលជាមធ្យោបាយដ៏ពេញនិយមនាពេលបច្ចុប្បន្ន ដែលអាចឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការអន្តរគ្រឹះស្ថាន និងផ្ទេរប្រាក់ចេញ-ចូលជាមួយបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់តាមរយៈប្រព័ន្ធបាគងបានយ៉ាងងាយស្រួល រហ័ស និងមានសុវត្ថិភាព។

### ៣.១.៣. ការអនុវត្តស្តង់ដាគណនេយ្យ

ធនាគារជាតិនៃកម្ពុជាបន្តរៀបចំទម្រង់របាយការណ៍ថ្មីៗស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់ដាក់ឱ្យគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើអនុវត្ត ដែលបច្ចុប្បន្ន ចំនួនរបាយការណ៍បានកើនឡើងដល់ ៥១ របាយការណ៍។ ជាមួយគ្នានេះដែរ ទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម ចំនួន ២៤ របាយការណ៍ ក៏កំពុងត្រូវបានរៀបចំសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផងដែរ។

ជាមួយគ្នានេះ ដើម្បីបន្តពង្រឹងគុណភាពទិន្នន័យ ជាពិសេសសង្គតិភាពទិន្នន័យ ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំស្តីពី ការផ្ទៀងផ្ទាត់សង្គតិភាពទិន្នន័យក្នុងរបាយការណ៍ត្រួតពិនិត្យ និងបានរៀបចំសិក្ខាសាលាស្តីពីរបាយការណ៍ត្រួតពិនិត្យទម្រង់ថ្មីចំនួន ២ លើក ដើម្បីផ្សព្វផ្សាយទម្រង់របាយការណ៍ថ្មី និងផ្តល់ជាវេទិកាដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពិភាក្សាអំពីការអនុវត្តនិងបញ្ហាប្រឈមដែលគ្រឹះស្ថានបានជួបប្រទះក្នុងអំឡុងពេលនៃការរាយការណ៍ក៏ដូចជាចែករំលែកអំពីកំហុសឆ្គងដែលកើតមានឡើងជាញឹកញាប់ក្នុងការរៀបចំរបាយការណ៍ទាំងនេះ។

បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តរៀបចំនិងអភិវឌ្ឍទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីៗបន្ថែមទៀត ស្របតាមការវិវត្តនៃបទដ្ឋានអន្តរជាតិ ស្ថានភាពហិរញ្ញវត្ថុសកល និងការកែសម្រួលបទប្បញ្ញត្តិជាធរមាន និងបន្តធ្វើបច្ចុប្បន្នកម្មការផ្ទៀងផ្ទាត់សង្គតិភាពនៅក្នុងរបាយការណ៍ត្រួតពិនិត្យបន្ថែមទៀត ព្រមទាំងបន្តការរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីជាប្រចាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ស្របជាមួយគ្នានេះ ផ្ទាំងបង្ហាញព័ត៌មានហិរញ្ញវត្ថុក៏បាននិងកំពុងរៀបចំនិងអនុវត្តជាបណ្តើរៗ សម្រាប់ពង្រឹងការតាមដានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការវិភាគស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តវិធានការជំបូងផ្នែករដ្ឋបាល តាមរយៈកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងរបស់គ្រឹះស្ថានដែលមិនអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងកាតព្វកិច្ចរាយការណ៍ ដែលរួមមានគ្រឹះស្ថានទាំងឡាយណាដែលមានភាពយឺតយ៉ាវក្នុងការបញ្ជូនរបាយការណ៍ និងមានកំហុសឆ្គងក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យប្រចាំគ្រាផងដែរ។ ធនាគារជាតិនៃកម្ពុជានឹងបន្តដាក់ចេញនូវវិធានការរដ្ឋបាលបន្ថែមទៀត ចំពោះគ្រឹះស្ថានទាំងឡាយណាដែលមិនអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងកាតព្វកិច្ចរាយការណ៍ ព្រមទាំងសិក្សាពីលទ្ធភាពក្នុងការកាត់បន្ថយកាលបរិច្ឆេទរាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីទទួលបានទិន្នន័យកាន់តែឆាប់រហ័ស និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានលទ្ធភាពក្នុងការផ្ទៀងផ្ទាត់ទិន្នន័យដោយស្វ័យប្រវត្តិ ដើម្បីសម្រួលដល់ការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងពង្រឹងបន្ថែមលើការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា តាមរយៈការធ្វើបច្ចុប្បន្នកម្មគេហទំព័រធនាគារជាតិនៃកម្ពុជា ដោយមានបន្ថែមនូវទិន្នន័យថ្មីៗ ដែលជាប្រយោជន៍សម្រាប់ក្រសួង-ស្ថាប័ន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទូទៅ។

### ៣.១.៤. ការចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ជាអ្នកផ្តល់សេវា និងគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលមានគ្រឹះស្ថានជាសមាជិកចំនួន ១៩៦ គ្រឹះស្ថាន[២] ក្នុងនោះ ធនាគារពាណិជ្ជ ៦១ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៧ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៣ និងគ្រឹះស្ថានឥណទានជនបទ ២១។

ក្រាហ្វ ៣២៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - គ្រឹះស្ថានជាសមាជិក




សំពៀតឥណទានសរុប ដែលអ្នកផ្តល់ទិន្នន័យបានបញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួនសរុប ២៤៩ ទ្រីលានរៀល (៦២ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៤.៥២៩.០១៣ គណនី ក្នុងនោះ៖ ១/-ឥណទានលក្ខណៈបុគ្គលមានចំនួន ២១៥,៨ ទ្រីលានរៀល (៥៣,៨ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៤.៥២២.០១៥ គណនី និង ២/-ឥណទានក្រុមហ៊ុនឬសហគ្រាសមានចំនួន ៣៣,២ ទ្រីលានរៀល (៨,៣ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៦.៩៩៨ គណនី។

[២] ចំនួនគ្រឹះស្ថានជាសមាជិកនេះ រួមបញ្ចូលទាំងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានជម្រះបញ្ជីរួចហើយ។

ក្រាហ្វ ៣៣ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទាន និងចំនួនគណនី




ទិន្នន័យឥណទានដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន រួមមាន៖ ធនាគារពាណិជ្ជ ២២២ ទ្រីលានរៀល (៥៥,៣ ប៊ីលានដុល្លារអាមេរិក) ធនាគារឯកទេស ២,៥ ទ្រីលានរៀល (៦១២,៦ លានដុល្លារអាមេរិក) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១៥,២ ទ្រីលានរៀល (៣,៨ ប៊ីលានដុល្លារអាមេរិក) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨ ទ្រីលានរៀល (២ ប៊ីលានដុល្លារអាមេរិក) គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១,២ ទ្រីលានរៀល (២៩៨,៧ លានដុល្លារអាមេរិក) និងគ្រឹះស្ថានឥណទានជនបទ ៩៨,៧ ប៊ីលានរៀល (២៤,៦ លានដុល្លារអាមេរិក)។

ក្រាហ្វ ៣៤៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទានបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក




គ្រឹះស្ថានជាសមាជិកបានចូលប្រើប្រាស់របាយការណ៍ឥណទាន សរុបមានចំនួន ៦,៥ លានប្រតិបត្តិការ ក្នុងនោះ៖ ធនាគារពាណិជ្ជ ៤,៣ លានប្រតិបត្តិការ (៦៥,៦%) ធនាគារឯកទេស ១៤៦,២ ពាន់ប្រតិបត្តិការ (២,២%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១ លានប្រតិបត្តិការ (១៤,៧%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៩៦២,៩ ពាន់ប្រតិបត្តិការ (១៤,៧%) គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ៥២,៧ ពាន់ប្រតិបត្តិការ (០,៨%) និងគ្រឹះស្ថានឥណទានជនបទ ៥២,៧ ពាន់ប្រតិបត្តិការ (០,៨%)។

ក្រាហ្វ ៣៥៖ អ្នកផ្ដល់សេវាចែករំលែកព័ត៌មានឥណទាន - ការប្រើប្រាស់របាយការណ៍ឥណទាន




ទន្ទឹមនេះ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យ មូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ចំនួន ៥.៧៣៤ ប្រតិបត្តិការ ដែលមានទឹកប្រាក់សរុប ១,៨ ទ្រីលានរៀល (៤៦២,៩ លានដុល្លារអាមេរិក)។

ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទានបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការសេវាចែករំលែករបាយការណ៍ព័ត៌មានឥណទានឆ្លងប្រទេស រួមមាន សិង្ហបុរី និងសាធារណរដ្ឋកូរ៉េ។ ជាមួយគ្នានេះ ដើម្បីលើកកម្ពស់ការប្រើប្រាស់របាយការណ៍ឥណទានឆ្លងប្រទេស ធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំគោលការណ៍ និងនីតិវិធីសម្រាប់ការប្រើប្រាស់របាយការណ៍ឥណទានឆ្លងប្រទេស។ ទន្ទឹមនេះ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី បាននិងកំពុងអភិវឌ្ឍ ខ្មែរ ស្ករ (K-Score) ដែលជាតួលេខវាស់ស្ទង់កម្រិតហានិភ័យឥណទានរបស់បុគ្គលនិងព្យាករពីលទ្ធភាពក្នុងការបង់សងត្រឡប់ និងបានទទួលការអនុញ្ញាតឱ្យដាក់ដំណើរការជាផ្លូវការពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា នឹងបន្តតាមដាន និងត្រួតពិនិត្យលើវឌ្ឍនភាពនៃការប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមានរបស់អ្នកផ្ដល់ទិន្នន័យ និងអ្នកផ្ដល់សេវាចែករំលែកព័ត៌មានឥណទានជាប្រចាំ សំដៅធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

## ៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តផែនការសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្ដីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ សំដៅពង្រីកលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងអត្ថប្រយោជន៍ពេញលេញសម្រាប់ប្រជាជន និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។ ក្រោមកិច្ចសហការជាមួយក្រសួង-ស្ថាប័ន

ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនពាក់ព័ន្ធ ធនាគារជាតិនៃកម្ពុជា បន្តជំរុញវឌ្ឍនភាពឆ្ពោះទៅរកប្រព័ន្ធអេកូហិរញ្ញវត្ថុមួយដែលប្រកបដោយសុវត្ថិភាព ភាពធន់ និងបរិយាបន្ន តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័ន ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ការជំរុញនវានុវត្តន៍ឌីជីថលលើប្រព័ន្ធទូទាត់និងផ្ទេរប្រាក់ និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

**ប្រអប់ទី២**

**សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទិវាសន្សំអាស៊ាន"**

ទិវាសន្សំអាស៊ាន លើកទី៦ ក្រោមប្រធានបទ "សន្សំប្រាក់ដោយភាពវៃឆ្លាត សន្សំប្រាក់ដោយក្តីស្រឡាញ់" ត្រូវបានរៀបចំឡើងនៅក្រុងកំពត ខេត្តកំពត ដែលមានអ្នកចូលរួមប្រមាណ ៦៧៤ នាក់។ ទិវាសន្សំអាស៊ានដែលត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនាថ្ងៃទី៣១ ខែតុលា គឺជាការផ្តួចផ្តើមរបស់ប្រទេសជាសមាជិកអាស៊ាន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីសារៈសំខាន់នៃការសន្សំប្រាក់ សំដៅជំរុញបរិយាបន្នហិរញ្ញវត្ថុនៅក្នុងប្រទេសជាសមាជិក។ ទិវានេះរួមបញ្ចូលនូវកម្មវិធីសំខាន់ៗដែលជាប្រយោជន៍ដល់សិស្សានុសិស្ស និងអ្នកចូលរួមទាំងអស់ ដូចជា ការប្រកួតប្រជែងរបស់សិស្សានុសិស្សមកពីវិទ្យាល័យក្នុងខេត្ត ដើម្បីបំផុសនិងជំរុញវប្បធម៌សន្សំប្រាក់ កិច្ចពិភាក្សាពីវាគ្មិនជំនាញមកពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អំពីសារៈសំខាន់នៃ "ទម្លាប់នៃការសន្សំប្រាក់" និងការតាំងពិព័រណ៍អំពីផលិតផលនិងសេវាកម្មសន្សំ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដល់សាធារណជន ដើម្បីបង្កើតឱ្យមានវប្បធម៌សន្សំប្រាក់ និងបង្កើនទំនុកចិត្តក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។

## ៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ

### ៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជា សហការជាមួយភាគីពាក់ព័ន្ធបានរៀបចំសិក្ខាសាលាស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" នៅតាមមូលដ្ឋាន សម្រាប់ថ្នាក់ខេត្តចំនួន ៤ រួមមាន៖ តាកែវ ក្រចេះ ស្ទឹងត្រែង និងកំពង់ឆ្នាំង ដោយមានអ្នកចូលរួមសរុបចំនួន ៧៥០ រូប។ សិក្ខាសាលានេះ ក៏បានរៀបចំសម្រាប់ថ្នាក់ក្រុង-ស្រុកចំនួន ៥ រួមមាន៖ ក្រុងឧដុង្គម៉ែជ័យ ស្រុកសន្ទុក ស្រុកប្រាសាទសំបូរ ស្រុកក្រគរ និងស្រុកទឹកផុស ដោយមានអ្នកចូលរួមសរុប ១.១៦២ រូប។ សិក្ខាសាលាមានគោលបំណងលើកកម្ពស់ការយល់ដឹងជូនដល់អាជ្ញាធរនៅតាមមូលដ្ឋាន ពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងកិច្ចការពារអតិថិជនដោយមានការចូលរួមពីវាគ្មិនជំនាញមកពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ បន្ថែមពីនេះ សិក្ខាសាលានេះ ផ្តល់ជាវេទិកាសម្រាប់ការពិភាក្សានិង

បកស្រាយនូវចម្ងល់ ក៏ដូចជាដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់ភាគីពាក់ព័ន្ធ។ ចំណុចសំខាន់ៗ និងបញ្ហាប្រឈមនៅតាមមូលដ្ឋាន ត្រូវបានប្រមូលចងក្រងជាធាតុចូលដើម្បីចាត់វិធានការកែតម្រូវ និងរៀបចំគោលនយោបាយចាំបាច់ដែលធានាផលប្រយោជន៍របស់អតិថិជន និងគ្រឹះស្ថាន។

### ៣.២.១.២. ការបញ្រ្ជាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ

គម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ដំណាក់កាលទី៣ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង ធនាគារជាតិនៃកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡា ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់សិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា ពីកម្រិតបឋមសិក្សា ដល់មធ្យមសិក្សា។ គម្រោងនេះ រួមបញ្ចូលផែនការសកម្មភាពមួយចំនួន រួមមាន៖ ១/-ការរៀបចំសៀវភៅសិស្សសម្រាប់ថ្នាក់ទី៧ ដល់ទី១១ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា ២/-ការរៀបចំសៀវភៅណែនាំសម្រាប់គ្រូថ្នាក់ទី៧ ដល់ទី១១ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា សម្រាប់ជាឯកសារជំនួយស្មារតីដល់គ្រូក្នុងការបង្រៀនសិស្ស ៣/-ការរៀបចំសៀវភៅលំហាត់សម្រាប់សិស្ស ដើម្បីសិស្សអាចស្វ័យសិក្សា និងបង្កើនចំណេះដឹងក្រៅម៉ោងសិក្សាគោល ៤/-ការរៀបចំវីដេអូណែនាំសម្រាប់សិស្សរៀនមិនទាន់ ឬខកខានមិនបានមករៀន ដែលមាតិកានៃវីដេអូដូចគ្នានឹងមាតិកានៃសៀវភៅសិស្សថ្មី ៥/-ការបង្រៀនសាកល្បងដោយប្រើប្រាស់ឯកសារនិងសម្ភារៈសិក្សាដែលបានរៀបចំនៅសាលារៀនគោលដៅចំនួន ១០ និង ៦/-ការវាយតម្លៃនៅពេលបញ្ចប់ឆ្នាំសិក្សា ដែលស្របតាមការធ្វើតេស្តស្តង់ដា PISA។

លើសពីនេះធនាគារជាតិនៃកម្ពុជា បានរៀបចំកម្មវិធីចែករំលែកចំណេះដឹងស្តីពី ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យមួយចំនួន និងសាខាធនាគារជាតិនៃកម្ពុជា ក្នុងខេត្តកំពង់ចាម ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ និងវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ។ កម្មវិធីនេះមានគោលបំណងផ្សព្វផ្សាយនិងបង្កើនចំណេះដឹងអំពីច្បាប់និងបទប្បញ្ញត្តិ ប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យធនាគារ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ប្រភេទគ្រឹះស្ថាននិងសេវាហិរញ្ញវត្ថុផ្លូវការ កម្ចីខុសច្បាប់និងការឆបោកផ្នែកហិរញ្ញវត្ថុ អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ប្រព័ន្ធបាគងនិងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់សេវាហិរញ្ញវត្ថុ ជូននិស្សិត-សាស្ត្រាចារ្យមកពីគ្រឹះស្ថានឧត្តមសិក្សា និងមន្ត្រី-បុគ្គលិកនៅសាខាធនាគារជាតិនៃកម្ពុជា សរុបប្រមាណ ៤.១០០ រូប។

### ៣.២.១.៣. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី

ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងសហគ្រិនស្ត្រី គឺជាការងារអាទិភាពមួយរបស់រាជរដ្ឋាភិបាល។ ដើម្បីរួមចំណែកក្នុងកិច្ចការងារនេះ ធនាគារជាតិនៃកម្ពុជាតែងតែសហការជាមួយក្រសួងកិច្ចការនារី តាមរយៈការចូលរួមរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពី "បរិយាបន្នហិរញ្ញវត្ថុ

សម្រាប់ស្ត្រី” ព្រមទាំងបានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី "តោះ ! និយាយអំពីហិរញ្ញវត្ថុ និងឌីជីថល” លើកទី៣ ក្រោមប្រធានបទ "ស្ថិរភាពហិរញ្ញវត្ថុ និងការរីកចម្រើនរយៈពេលវែង” ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី នៃក្រសួងកិច្ចការនារី។

### ៣.២.១.៤. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយៈ គក់ៗពេញចំពង់”

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយអង្គការ Good Return ដើម្បីរៀបចំគម្រោង "តោះ ! និយាយពីលុយ” ដំណាក់កាលទី៣ ក្រោមប្រធានបទ "ការបង្កើនជំនាញហិរញ្ញវត្ថុឌីជីថល” ដោយផ្ដោតលើការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលប្រកបដោយសុវត្ថិភាពនិងទំនុកចិត្ត ការការពារខ្លួនពីការឆបោកផ្នែកហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ និងការប្រើប្រាស់កម្មវិធីទូរសព្ទ (My Money Tracker) ដើម្បីសន្សំប្រាក់។ គួររំលេចថា គម្រោងដំណាក់កាលទី១ និងទី២ ត្រូវបានបញ្ចប់ជាស្ថាពរកាលពីឆ្នាំ២០១៦ និងឆ្នាំ២០២១។

### ៣.២.១.៥. គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍”

គម្រោងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍ បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងសុវត្ថិភាពការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនៅតាមសហគមន៍ស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងការអនុវត្តគម្រោងនេះ គ្រូបង្គោលចំនួន ៥៩ រូប នៅតាមសហគមន៍ត្រូវបានពង្រឹងសមត្ថភាពបន្ថែម និងមុខវិជ្ជាចំនួន ៥ ត្រូវបានបង្កើតឡើង។ ការផ្សព្វផ្សាយការលើកកម្ពស់ចំណេះដឹងជាសាធារណៈត្រូវបានរៀបចំឡើងចំនួន ១.២៤២ លើក ដោយមានអ្នកចូលរួមសរុប ២៩.៣៥៣ រូប (ស្ត្រី ២២.១៣៦ រូប) ដែលជាកសិករ និងម្ចាស់អាជីវកម្មខ្នាតតូច។ គណៈកម្មាធិការកណ្ដាលត្រូវបានបង្កើតឡើង ដើម្បីតាមដានវឌ្ឍនភាព សមិទ្ធផល ផលប៉ះពាល់ ដំណោះស្រាយ និងរៀបចំផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់ ដោយមានបុគ្គលិកចុះត្រួតពិនិត្យ និងតាមដានការអនុវត្តជាប់ជាប្រចាំ ដើម្បីសម្របសម្រួលនិងបំពាក់បំប៉នគ្រូបង្គោលបន្ថែម។ បន្ថែមលើគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍” ដំណាក់កាលដំបូងនៅក្នុងឃុំចំនួន ៤ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បាននិងកំពុងបន្តរៀបចំគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុសហគមន៍” ដំណាក់កាលទី២ នៅទីតាំងគោលដៅចំនួន ៤ ទៀត រួមមាន៖ ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និង ឃុំល្អក់ ស្រុកអូរជុំ ខេត្តរតនគិរី។

### ៣.២.២. កិច្ចការពារអតិថិជន

ដើម្បីរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជន ក៏ដូចជាចូលរួមដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវានិងផលិតផលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព

ទាន់ពេលវេលា និងមានសង្គតិភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូរសព្ទហាតឡាញចំនួន ២៦ ខ្សែ (ទីស្នាក់ការកណ្តាលចំនួន ៥ ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ២១ ខ្សែ) ដើម្បីផ្តល់លទ្ធភាពបន្ថែមដល់អ្នកប្រើប្រាស់អាចដាក់ពាក្យបណ្តឹង ស្នើសុំការអន្តរាគមន៍ ឬសាកសួរព័ត៌មានផ្សេងៗពាក់ព័ន្ធការប្រើប្រាស់សេវានិងផលិតផលហិរញ្ញវត្ថុ។

ក្នុងឆ្នាំ២០២៥ មន្ត្រីទទួលបន្ទុកហាតឡាញធនាគារជាតិនៃកម្ពុជា បានទទួលបណ្តឹងនិងការសាកសួរសរុបចំនួន ៧២១ ករណី (ទីស្នាក់ការកណ្តាលមានចំនួន ៥៣៣ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត មានចំនួន ១៨៨ ករណី) ក្នុងនោះ ៦៨៣ ករណី (៩៤,៧%) ត្រូវបានដោះស្រាយរួចរាល់ ១២ ករណី(១,៧%) កំពុងត្រូវបានដោះស្រាយ និង ២៦ ករណីផ្សេងទៀត (៣,៦%) កំពុងស្ថិតក្នុងនីតិវិធីតុលាការ។ បណ្តឹងនិងការសាកសួរទាំងនេះ ពាក់ព័ន្ធនឹង៖ ១/-ការពិន័យលើការបង់ផ្តាច់ឥណទានមុនកាលកំណត់ ២/-ការស្នើសុំរៀបចំឥណទានឡើងវិញ ៣/-កម្ចីខុសច្បាប់ ៤/-ការឆបោកផ្នែកហិរញ្ញវត្ថុ ៥/-ការស្នើសុំអនុគ្រោះលក្ខខ័ណ្ឌទូទាត់ ៦/-ការស្នើសុំដំណើរការគណនីដែលបានបង្កក ៧/-ការដកប្រាក់បញ្ញើពីគ្រឹះស្ថានដែលកំពុងត្រូវបានជម្រះបញ្ជី ៨/-ការស្នើសុំកែតម្រូវព័ត៌មានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និង ៩/-ការយឺតយ៉ាវក្នុងការដកទ្រព្យធានា។

គួររំលេចផងដែរថា កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ក្រសួងមហាផ្ទៃ ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានចេញសេចក្តីថ្លែងការណ៍រួម ស្តីពី "ការចាត់វិធានការចំពោះសកម្មភាពផ្តល់កម្ចីខុសច្បាប់ និងការទទួលយកអត្តសញ្ញាណបណ្ណ សៀវភៅស្នាក់នៅ ប័ណ្ណសមធម៌ និងបណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម សម្រាប់ធានាលើកម្ចី"។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បន្តពង្រឹងយន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងអតិថិជនតាមរយៈការពិនិត្យនិងកែសម្រួលឡើងវិញនូវប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីឱ្យស្របនឹងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងការវិវត្តន៍នៃប្រព័ន្ធធនាគារ។

### ៣.២.៣. កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ ស្តីពី "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា"

កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយភាគីពាក់ព័ន្ធ លើកទី៣ ស្តីពី "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាង ធនាគារជាតិនៃកម្ពុជា និងអង្គការសហប្រជាជាតិនៅកម្ពុជា ក្នុងគោលបំណងសម្របសម្រួលឱ្យមានការចូលរួមពិភាក្សាក្នុងន័យស្ថាបនាពីភាគីពាក់ព័ន្ធ បង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីបញ្ហាប្រឈមនានា និងកំណត់សកម្មភាពនិងការប្តេជ្ញាចិត្តជាក់លាក់ ដែលអាចគាំទ្រដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការដោះស្រាយបញ្ហាបំណុលលើសលប់ និងចាប់យកកាលានុវត្តភាពក្នុងការពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុ។

ទន្ទឹមនេះ កិច្ចពិគ្រោះយោបល់ ស្តីពី "ការចូលរួមរបស់វិនិយោគិនប្រកបដោយការទទួលខុសត្រូវ" ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តោតលើក្របខ័ណ្ឌអភិបាលកិច្ចដែលមានស្រាប់ និងភាពខ្វះចន្លោះ ដែលចំណុចទាំងអស់នោះអាចនឹងយកមកកសាងជាទិសដៅយុទ្ធសាស្ត្រមួយក្នុងការអនុវត្តរបស់វិនិយោគិនឱ្យស្របទៅនឹងចក្ខុវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព និងផ្តោតទៅលើការជឿទុកចិត្ត ការទទួលខុសត្រូវរួម និងកំណើនប្រកបដោយបរិយាបន្ន។

## ៤. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការ

### ៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ

ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៅក្នុងវិស័យហិរញ្ញវត្ថុ និងបំពេញតម្រូវការក្នុងការបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យ ការបណ្តុះបណ្តាលដោយផ្ទាល់និងប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យបានផ្តោតលើការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក ជាពិសេសមន្ត្រីបុគ្គលិកដែលទើបត្រូវបានជ្រើសរើសលើប្រធានបទពាក់ព័ន្ធតាមរយៈបទបង្ហាញ ការចែករំលែកបទពិសោធនិងចំណេះដឹងដោយមន្ត្រីត្រួតពិនិត្យដែលមានបទពិសោធ និងមន្ត្រីត្រួតពិនិត្យដែលបានទទួលការបណ្តុះបណ្តាលវគ្គខ្លីៗនៅក្រៅប្រទេស។ អគ្គនាយកដ្ឋានត្រួតពិនិត្យក៏បានពិនិត្យលទ្ធភាពបន្ថែម ដើម្បីស្វែងរកវាគ្មិនពីខាងក្រៅដែលជាអ្នកអនុវត្តផ្ទាល់។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុលើប្រធានបទចំនួន ២ គឺ៖ ១/-ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ២/-របាយការណ៍ត្រួតពិនិត្យ ដែលត្រូវបញ្ចូលក្នុងប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ។ បន្ថែមពីនេះ អគ្គនាយកដ្ឋានត្រួតពិនិត្យ ក៏បានរៀបចំវគ្គចែករំលែកចំនួន ២ ជូនដល់អាជ្ញាធរជាតិ និងអន្តរជាតិ រួមមាន៖ ១/-ការចែករំលែកបទពិសោធ អំពីការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដល់និយ័តករសន្តិសុខសង្គម និង ២/-ការចែករំលែកបទពិសោធអំពីការត្រួតពិនិត្យក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ដល់ប្រទេសចំនួន ៣ មកពីតំបន់ប៉ាស៊ីហ្វិក រួមមាន៖ ១/-ប៉ាពូអាស៊ីនូវែលហ្គីណេ ២/-កោះសូឡូម៉ូន និង ៣/-វ៉ានូទូ។

ក្រៅពីវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងវគ្គចែករំលែកចំណេះដឹងផ្ទៃក្នុង មន្ត្រីត្រួតពិនិត្យក៏បានចូលរួមដោយផ្ទាល់ក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធ ក្នុងប្រទេសនិងក្រៅប្រទេស ដែលរៀបចំដោយស្ថាប័នអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលស៊ាសិន ជាដើម។

## ៤.២. កិច្ចសហប្រតិបត្តិការជាតិ

### ៤.២.១. អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ក្នុងការអនុវត្តការងារចម្បងៗមួយចំនួន ដូចជា៖ ការចែករំលែកព័ត៌មាន ការដាក់ទណ្ឌកម្មចំពោះគ្រឹះស្ថានមិនគោរពតាមច្បាប់និងបទប្បញ្ញត្តិ ការប្រជុំពិភាក្សា ការចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាពអាវុធមហាប្រល័យ ព្រមទាំងបានចូលរួមក្នុងក្រុមការងារវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២។

### ៤.២.២. កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងទទួលការស្នើសុំកិច្ចសហការសម្របសម្រួលក្នុងការស្រាវជ្រាវព័ត៌មានគណនីអតិថិជន ការបង្កកនិងការលើកលែងការបង្កកគណនី ពីស្ថាប័នពាក់ព័ន្ធ ក្នុងការជួយសម្រួលដល់ការប្រមូលពន្ធអាករ ការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ និងការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ នៅក្នុងឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជា បានផ្តល់កិច្ចសហការសរុបចំនួន ២៧០ ករណី ក្នុងនោះក្រសួងយុត្តិធម៌និងសាលាដំបូងមានសមត្ថកិច្ច ១៥៣ ករណី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ ១០៩ ករណី ក្រសួងមហាផ្ទៃ ១ ករណី អគ្គស្នងការដ្ឋាននគរបាលជាតិ ២ ករណី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១ ករណី និងស្ថាប័នផ្សេងៗ ៤ ករណី។ ក្នុងចំណោមសំណើសុំកិច្ចសហការទាំងនេះ ធនាគារជាតិនៃកម្ពុជា បានសម្របសម្រួលក្នុងការស្រាវជ្រាវព័ត៌មានគណនីអតិថិជនចំនួន ១៤២ ករណី ការបង្កកគណនីចំនួន ៥៨ ករណី ការលើកលែងការបង្កកគណនីចំនួន ៣៩ ករណី និងករណីផ្សេងៗចំនួន ៤ ករណី។ ក្រៅពីនេះ សំណើសុំកិច្ចសហការចំនួន ៨២២ ករណីទៀត ត្រូវបានស្ថាប័នតុលាការនិងអគ្គស្នងការដ្ឋាននគរបាលជាតិស្នើសុំអនុវត្តដោយផ្ទាល់ទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ៤.២.៣. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ស្វែងរកដំណោះស្រាយជួយសម្រាលបន្ទុកហិរញ្ញវត្ថុដល់អតិថិជនជាជនភៀសសឹកយោធិនដែលធ្វើប្រតិបត្តិការដោយផ្ទាល់ក្នុងសមរភូមិប្រយុទ្ធ និងអតិថិជនផ្សេងទៀតដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ តាមលទ្ធភាពជាក់ស្តែងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជា បានគាំទ្រគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា លើការរៀបចំស្វ័យបញ្ញត្តិ រួមមាន៖ i/-វិសោធនកម្មស្តង់ដាកិច្ចសន្យាឥណទានសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ ii/-ក្របខ័ណ្ឌនៃការផ្តល់ការលើកទឹកចិត្តសម្រាប់មន្ត្រីពាក់ព័ន្ធនឹងផ្នែកឥណទាន iii/-គោលការណ៍ណែនាំស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីពាក់ព័ន្ធនឹងផ្នែកឥណទាន និង iv/-និយមន័យប្រតិបត្តិការឥណទានខ្នាតមីក្រូសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមសហការជាមួយសមាគមទាំងពីរ ក្នុងការរៀបចំកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុមួយចំនួនរួមមាន៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន និងទិវាសន្សំអាស៊ាន ជាដើម។

## ៤.៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៤.៣.១. គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ

ក្នុងឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានរៀបចំសេចក្តីព្រាងផែនទីចង្អុលទិសហិរញ្ញវត្ថុប្រកបដោយចីរភាពសម្រាប់កម្ពុជា ដោយផ្អែកលើសសរស្តម្ភចំនួន ៣ រួមមាន៖ ១/-ការបង្កើតឱ្យមានលក្ខខណ្ឌអំណោយផលសម្រាប់ជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព ២/-ការពង្រឹងសមត្ថភាពនៃអ្នកផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាព (Supply Side) និង ៣/-ការជំរុញផ្នែកតម្រូវការហិរញ្ញវត្ថុប្រកបដោយចីរភាព។ ការងារនេះ ជាផ្នែកមួយនៃអនុស្សរណៈនៃការយោគយល់គ្នារវាងធនាគារជាតិនៃកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌអនុវត្តសម្រាប់លើកកម្ពស់ការវិនិយោគប្រកបដោយចីរភាពនៅកម្ពុជា តាមរយៈការកៀរគរហិរញ្ញវត្ថុបៃតងនិងហិរញ្ញវត្ថុប្រកបដោយចីរភាពដើម្បីគាំទ្រដល់គម្រោងពាក់ព័ន្ធនឹងការទប់ស្កាត់ផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ ផែនទីចង្អុលទិសនេះ នឹងត្រូវប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០២៦ខាងមុខ។

### ៤.៣.២. សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បន្តកិច្ចសហការជិតស្និទ្ធជាមួយសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ ក្នុងការចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ប្រទេសជាសមាជិកទាំងអស់ រួមទាំងកម្ពុជាផង។ ជាក់ស្តែង ថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំពាក់ព័ន្ធរបស់សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២-៥ ខែកញ្ញា ឆ្នាំ២០២៥ នៅទីក្រុង Swakopmund ប្រទេសណាមីប៊ី។ កិច្ចប្រជុំនេះត្រូវបានរៀបចំជារៀងរាល់ឆ្នាំដើម្បីចែករំលែកនូវចំណេះដឹង ទស្សនាទាន និងបទពិសោធទាក់ទងនឹងការវិវឌ្ឍថ្មីៗនៃសេដ្ឋកិច្ចសាកល បញ្ហាប្រឈម និងដំណោះស្រាយនានា ក្នុងទិសដៅជំរុញបរិយាបន្នហិរញ្ញវត្ថុក្នុងតំបន់។

ក្នុងកម្មវិធីខាងលើ លោកជំទាវ ទេសាភិបាល ក៏បានចែករំលែកពីបទពិសោធនៃភាពជាអ្នកដឹកនាំដល់អ្នកដឹកនាំវ័យក្មេងរបស់ប្រទេសមួយចំនួនដែលជាសមាជិក ព្រមទាំងបទពិសោធនិងគំនិតផ្តួចផ្តើមថ្មីៗពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។

## ៤.៣.៣. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ លើការអនុវត្តគម្រោងស្តីពី កិច្ចការពារអតិថិជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីពិនិត្យឡើងវិញលើការរៀបចំ និងដាក់ចេញនូវបទប្បញ្ញត្តិ និងពង្រឹងការត្រួតពិនិត្យពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន តាមរយៈការរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ដល់ភាគីពាក់ព័ន្ធ រួមមាន៖ មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា និងតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំប្រកាសស្តីពី ក្របខ័ណ្ឌដោះស្រាយបណ្តឹងអតិថិជន។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពី បទប្បញ្ញត្តិក្រមប្រតិបត្តិទីផ្សារ និងកិច្ចការពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុ ចំនួន ២ លើក សម្រាប់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាដែលធ្វើការពាក់ព័ន្ធផងដែរ។

ទន្ទឹមនេះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិក៏បានរួមចំណែកផ្តល់ជាធាតុចូលសម្រាប់ការរៀបចំ និងបង្កើតមជ្ឈមណ្ឌលអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលមានតួនាទីទទួលបន្ទុកប្រឹក្សា គ្រប់គ្រង និងដោះស្រាយពាក្យបណ្តឹងអតិថិជនក្នុងវិស័យធនាគារ។ មជ្ឈមណ្ឌលអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ត្រូវបានផ្តួចផ្តើមឡើងដោយ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រោមកិច្ចគាំទ្ររបស់ធនាគារជាតិនៃកម្ពុជា។

ជាមួយគ្នានេះផងដែរ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិក្នុងការរៀបចំប្រព័ន្ធវគ្គីករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីបង្កើតប្រព័ន្ធចាត់ថ្នាក់រួមមួយក្នុងការកំណត់សកម្មភាព ឬគម្រោងដែលមានចីរភាព សម្រាប់ជាថ្នាលជំនួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតងក្នុងប្រទេសកម្ពុជា។ ជាក់ស្តែង ក្នុងឆ្នាំ២០២៥នេះ ក្រុមការងារធនាគារជាតិនៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានសហការប្រមូលធាតុចូលពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាអំពីវិស័យអាទិភាព។ ជាលទ្ធផល ក្រុមការងារបានកំណត់យកវិស័យចំនួន ៣ សម្រាប់ដំណាក់កាលទី១ រួមមាន៖ ១/-វិស័យថាមពល ២/-វិស័យដឹកជញ្ជូន និង៣/-វិស័យសំណង់។ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងប្រព័ន្ធវគ្គីករសាស្ត្រសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សមាគម វិនិយោគិន និងអង្គការសង្គមស៊ីវិល ដើម្បីធានាថាប្រព័ន្ធវគ្គីករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជានេះស្របជាមួយបរិបទជាក់ស្តែងនៅកម្ពុជា និងមានភាពគ្រប់ជ្រុងជ្រោយ។ ប្រព័ន្ធវគ្គីករសាស្ត្រនេះគ្រោងនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០២៦។

លើសពីនេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តសហការជាមួយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ លើការងារសំខាន់ៗមួយចំនួនទៀត រួមមាន៖ ការសិក្សាលើការពង្រីកវិសាលភាពនៃប្រព័ន្ធវគ្គីករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពសម្រាប់វិស័យអាទិភាពផ្សេងទៀត ការកសាងសមត្ថភាពមន្ត្រីធនាគារជាតិ

នៃកម្ពុជា និងបុគ្គលិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការរៀបចំទម្រង់របាយការណ៍ និងការបង្ហាញរបាយការណ៍អំពីហិរញ្ញវត្ថុប្រកបដោយចីរភាព ការអភិវឌ្ឍគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។

### ៤.៣.៤. កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិផ្សេងៗ

ក្នុងការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ធនាគារជាតិនៃកម្ពុជា បាននិងបន្តផ្តល់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិរួមមាន៖ មូលនិធិរូបិយវត្ថុអន្តរជាតិ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ភ្នាក់ងារវាយតម្លៃ S&P Global Ratings ភ្នាក់ងារវាយតម្លៃ Andersen និងក្រុមហ៊ុន Tris Rating ក្នុងការផ្លាស់ប្តូរបទពិសោធ ចំណេះដឹង និងស្តង់ដាត្រួតពិនិត្យជាដើម។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងបន្តសហការជាមួយភាគីពាក់ព័ន្ធ ដូចជា អង្គការសហប្រជាជាតិ ដើម្បីដោះស្រាយបញ្ហាជំពាក់បំណុលលើសលប់។

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ឆ្នាំ២០២៥

ឧបសម្ព័ន្ធ ២ ប្រព័ន្ធធនាគារនៅកម្ពុជា

ឧបសម្ព័ន្ធ ៣ បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ៤ បញ្ជីឈ្មោះគ្រឹះស្ថានឥណទានជនបទដែលត្រូវបានបញ្ឈប់ប្រតិបត្តិការក្នុងឆ្នាំ២០២៥

ឧបសម្ព័ន្ធ ៥ បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពីឆ្នាំ២០២១-២០២៥

ឧបសម្ព័ន្ធ ៦ បញ្ជីលេខទូរស័ព្ទទំនាក់ទំនងអំពីចម្ងល់ និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ

## ឧបសម្ព័ន្ធ ១

# ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើនៅកម្ពុជា ឆ្នាំ២០២៥

## របាយការណ៍ស្តីពី ចំនួនសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

កាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

តារាង ១

| | | ២០២៥ | | | ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | សរុប[១] | រាជធានីភ្នំពេញ | ខេត្ត | សរុប[១] | រាជធានីភ្នំពេញ | ខេត្ត |
| **ល.រ** | **ធនាគារពាណិជ្ជ** | | | | | | |
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | **265** | 21 | 244 | **265** | 21 | 244 |
| ២ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | **104** | 37 | 67 | **99** | 34 | 65 |
| ៣ | ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | **3** | 2 | 1 | **2** | 1 | 1 |
| ៤ | ធនាគារពាណិជ្ជ អាល់ហ្វា ម.ក | **1** | 1 | - | **1** | 1 | - |
| ៥ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | **4** | 4 | - | **4** | 4 | - |
| ៦ | ធនាគារ បាងកក មហាជនទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | **1** | 1 | - | **1** | 1 | - |
| ៧ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | **8** | 6 | 2 | **8** | 6 | 2 |
| ៨ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | **5** | 3 | 2 | **5** | 3 | 2 |
| ៩ | ធនាគារ ប៊ូយ៉ុង ខ្មែរ | **4** | 2 | 2 | **4** | 2 | 2 |
| ១០ | សាខាធនាគារ អ៊ិនដាសស្ទ្រៀល បែ៊ង អហ្វ ខូរៀ "ភ្នំពេញ" | **1** | 1 | - | **1** | 1 | - |
| ១១ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | **1** | 1 | - | **1** | 1 | - |
| ១២ | សាខាធនាគារ មីហ្សូហូ អិលធីឌី | **1** | 1 | - | **1** | 1 | - |
| ១៣ | ធនាគារ ប្រេដ បែ៊ង (ខេមបូឌា) ភីអិលស៊ី | **15** | 12 | 3 | **15** | 12 | 3 |
| ១៤ | ធនាគារ ប្រ៊ីដ ម.ក | **5** | 4 | 1 | **4** | 3 | 1 |
| ១៥ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | **8** | 3 | 5 | **8** | 3 | 5 |
| ១៦ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | **64** | 14 | 50 | **64** | 14 | 50 |
| ១៧ | ធនាគារ កម្ពុជាពាណិជ្ជ ម.ក | **4** | 1 | 3 | **4** | 1 | 3 |
| ១៨ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | **33** | 21 | 12 | **33** | 21 | 12 |
| ១៩ | ធនាគារ កាណាឌីយ៉ា ក.អ | **69** | 33 | 36 | **68** | 33 | 35 |
| ២០ | ធនាគារ កាថេយូណៃធីត (ខេមបូឌា) ម.ក | **15** | 10 | 5 | **15** | 10 | 5 |
| ២១ | ធនាគារ ស៊ីស៊ីយូ ខមមើសល បែ៊ង ម.ក | **2** | 2 | - | **1** | 1 | - |
| ២២ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | **5** | 5 | - | **5** | 5 | - |
| ២៣ | ធនាគារ ជីប ម៉ុង ខមមើសល បែ៊ង ម.ក | **15** | 12 | 3 | **15** | 12 | 3 |
| ២៤ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | **14** | 10 | 4 | **14** | 10 | 4 |
| ២៥ | ធនាគារ ឌីជីប៊ី ម.ក | **10** | 9 | 1 | **10** | 9 | 1 |
| ២៦ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ | **10** | 9 | 1 | **10** | 9 | 1 |
| ២៧ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | **25** | 17 | 8 | **23** | 16 | 7 |
| ២៨ | ធនាគារ ហត្ថា ម.ក | **156** | 13 | 143 | **161** | 12 | 149 |
| ២៩ | ធនាគារ ហោង ហ្វឹង (ខេមបូឌា) ម.ក | **3** | 2 | 1 | **3** | 2 | 1 |
| ៣០ | ធនាគារ អេចអេច (ខេមបូឌា) ម.ក | **3** | 2 | 1 | **2** | 1 | 1 |
| ៣១ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | **7** | 7 | - | **7** | 7 | - |
| ៣២ | ធនាគារ អាយបែ៊ង (ខេមបូឌា) ម.ក | **6** | 5 | 1 | **5** | 4 | 1 |
| ៣៣ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | **1** | 1 | - | **1** | 1 | - |
| ៣៤ | ធនាគារ អាយភីយូ ស៊ី បែ៊ង (ខេមបូឌា) ម.ក | **1** | 1 | - | **1** | 1 | - |
| ៣៥ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | **17** | 13 | 4 | **17** | 13 | 4 |
| ៣៦ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | **187** | 23 | 164 | **188** | 24 | 164 |
| ៣៧ | ធនាគារ ក្រុងថៃ ចំកាត់ មហាជន សាខាភ្នំពេញ | **2** | 1 | 1 | **2** | 1 | 1 |
| ៣៨ | ធនាគារ មេយបែ៊ង (ខេមបូឌា) ភីអិលស៊ី | **21** | 13 | 8 | **21** | 13 | 8 |
| ៣៩ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក | **6** | 5 | 1 | **4** | 4 | - |
| ៤០ | ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល បែ៊ង ខូ អិលធីឌី សាខាភ្នំពេញ | **6** | 5 | 1 | **6** | 5 | 1 |
| ៤១ | ធនាគារ អូរៀនថល ម.ក | **3** | 3 | - | **3** | 3 | - |
| ៤២ | ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក* | **4** | 3 | 1 | **3** | 2 | 1 |
| ៤៣ | ធនាគារ ភីក វេល ម.ក | **3** | 1 | 2 | **2** | 1 | 1 |
| ៤៤ | ធនាគារ ហ្វីលីព ភីអិលស៊ី | **71** | 11 | 60 | **72** | 10 | 62 |
| ៤៥ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | **26** | 17 | 9 | **25** | 17 | 8 |
| ៤៦ | ធនាគារ ព្រីនស៍ ម.ក* | **37** | 14 | 23 | **36** | 13 | 23 |
| ៤៧ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | **12** | 8 | 4 | **12** | 8 | 4 |
| ៤៨ | ធនាគារ សាយហ្គន ធឿងទីន (ខេមបូឌា) ភីអិលស៊ី ហៅ ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី | **4** | 3 | 1 | **10** | 7 | 3 |
| ៤៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី | **4** | 4 | - | **4** | 4 | - |
| ៥០ | ធនាគារ ស្ថាបនា ភីអិលស៊ី | **175** | 25 | 150 | **175** | 26 | 149 |
| ៥១ | ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក | **52** | 9 | 43 | **50** | 9 | 41 |
| ៥២ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | **15** | 13 | 2 | **15** | 13 | 2 |
| ៥៣ | ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក "ធ.ស.ក" | **8** | 2 | 6 | **8** | 2 | 6 |
| ៥៤ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | **8** | 6 | 2 | **8** | 6 | 2 |
| ៥៥ | ធនាគារ សហពាណិជ្ជ ក.អ | **15** | 12 | 3 | **14** | 12 | 2 |
| ៥៦ | ធនាគារ វឌ្ឍនៈ | **43** | 15 | 28 | **41** | 15 | 26 |
| ៥៧ | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីបែ៊ង) | **1** | 1 | - | **1** | 1 | - |
| ៥៨ | ធនាគារ វីង (ខេមបូឌា) ម.ក | **27** | 15 | 12 | **24** | 13 | 11 |
| ៥៩ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក | **140** | 26 | 114 | **143** | 25 | 118 |
| | **សរុបផ្នែកធនាគារពាណិជ្ជ** | **1,756** | **521** | **1,235** | **1,745** | **510** | **1,235** |
| **ល.រ** | **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | | | |
| ១ | អេ អឹម ខេ ភីអិលស៊ី | **143** | 9 | 134 | **143** | 10 | 133 |
| ២ | អម្រឹត ម.ក | **150** | 15 | 135 | **150** | 15 | 135 |
| ៣ | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | **83** | 7 | 76 | **83** | 7 | 76 |
| ៤ | មហានគរ ម.ក | **59** | 8 | 51 | **60** | 8 | 52 |
| | **សរុបផ្នែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | **435** | **39** | **396** | **436** | **40** | **396** |
| | **សរុបរួម** | **2,191** | **560** | **1,631** | **2,181** | **550** | **1,631** |

*[១] រួមបញ្ចូលទាំងទីស្នាក់ការកណ្តាល*

**ធនាគារ ព្រីនស៍ ម.ក និង ធនាគារ ផេនដា ខមមើសល បែ៊ង ម.ក ត្រូវបានដកហូតអាជ្ញាបណ្ណនាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ និងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ រៀងគ្នា*

## របាយការណ៍ស្តីពី ចំនួនបុគ្គលិក

តារាង ២

| ល.រ | | ២០២៥ | ២០២៤ | %∆ |
|---|---|---|---|---|
| ល.រ | **ធនាគារពាណិជ្ជ** | | | |
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | 11,859 | 11,971 | -0.9% |
| ២ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 10,861 | 9,705 | 11.9% |
| ៣ | ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | 401 | 380 | 5.5% |
| ៤ | ធនាគារពាណិជ្ជ អាល់ហ្វា ម.ក | 72 | 66 | 9.1% |
| ៥ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | 461 | 427 | 8.0% |
| ៦ | ធនាគារ បាងកក មហាជនទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | 30 | 31 | -3.2% |
| ៧ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | 328 | 329 | -0.3% |
| ៨ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | 224 | 220 | 1.8% |
| ៩ | ធនាគារ ប៊ូយ៉ុង ខ្មែរ | 42 | 44 | -4.5% |
| ១០ | សាខាធនាគារ អ៊ិនដាសស្រៀល បែ៊ង អហ្វ ខូរៀ "ភ្នំពេញ" | 30 | 31 | -3.2% |
| ១១ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | 40 | 45 | -11.1% |
| ១២ | សាខាធនាគារ មីហ៊្សូហូ អិលធីឌី | 7 | 7 | - |
| ១៣ | ធនាគារ ប្រេដ បែ៊ង (ខេមបូឌា) ភីអិលស៊ី | 328 | 368 | -10.9% |
| ១៤ | ធនាគារ ប្រ៊ីដ ម.ក | 162 | 160 | 1.3% |
| ១៥ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | 322 | 338 | -4.7% |
| ១៦ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 2,180 | 2,113 | 3.2% |
| ១៧ | ធនាគារ កម្ពុជាពាណិជ្ជ ម.ក | 84 | 85 | -1.2% |
| ១៨ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | 897 | 926 | -3.1% |
| ១៩ | ធនាគារ កាណាឌីយ៉ា ក.អ | 4,167 | 4,332 | -3.8% |
| ២០ | ធនាគារ កាថេយូណៃធីត (ខេមបូឌា) ម.ក | 567 | 620 | -8.5% |
| ២១ | ធនាគារ ស៊ីស៊ីយូ ខមមើសល បែ៊ង ម.ក | 136 | 138 | -1.4% |
| ២២ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | 208 | 180 | 15.6% |
| ២៣ | ធនាគារ ជីប ម៉ុង ខមមើសល បែ៊ង ម.ក | 501 | 493 | 1.6% |
| ២៤ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | 502 | 497 | 1.0% |
| ២៥ | ធនាគារ ឌីជីប៊ី ម.ក | 505 | 548 | -7.8% |
| ២៦ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ | 182 | 183 | -0.5% |
| ២៧ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | 762 | 765 | -0.4% |
| ២៨ | ធនាគារ ហត្ថា ម.ក | 3,357 | 3,689 | -9.0% |
| ២៩ | ធនាគារ ហុង ហ្វឹង (ខេមបូឌា) ម.ក | 191 | 169 | 13.0% |
| ៣០ | ធនាគារ អេចអេច (ខេមបូឌា) ម.ក | 124 | 116 | 6.9% |
| ៣១ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | 159 | 205 | -22.4% |
